# គោលជំនឿស្ដីពីប្រវត្តនៃព្រះគម្ពីរ

## ប្រវត្តព្រះគម្ពីរសញ្ញាចាស់

(ការលាតត្រដាងសម្ព័ន្ធមេត្រីនៃសេចក្ដីសន្យារបស់ព្រះជាម្ចាស់)

ថ្នាក់ខ្ពស់ (កំរិត ៣)
ភាគទី ១

រៀបរៀងដោយលោកគ្រូគង្វាល ចន អា. ហ៊ីស
ត្រួតពិនិត្យដោយលោកគ្រូគង្វាល ជេ. ជេ. លិម

Copyright © Gratia Dei Sola Media

# អារម្ភកថាអ្នកនិពន្ធ

ចំណុចសំខាន់នៃសៀវភៅនេះ ជាមូលដ្ឋានគ្រឹះដោយផ្អែកលើគោលការណ៍ ដែលមានចែងនៅក្នុងព្រះគម្ពីរលោកុប្បត្តិ ៣:១៥ ដែលជាសេចក្តីសន្យាដើម វាគឺជាការជូនដំណឹងមុនគេអំពីសេចក្តីសន្យានៃដំណឹងល្អ ហើយនៅក្នុងព្រះគម្ពីរនៃសម្ពន្ធមេត្រីចាស់ទាំងអស់ ជាការលាតត្រដាងអំពីសេចក្តីសន្យានោះ។

ហេតុដូច្នេះហើយ បានជាយើងធ្វើការបែកចែកជាច្រើនសម័យកាល ដោយចាប់តាំងពីកំណើតពីភពលោកមកទល់នឹងព្រះយេស៊ូគ្រីស្ទ គឺមានរហូតទៅដល់ ៥សម័យកាលឯណោះ។

នៅទីបញ្ចប់នៃសម័យកាលនីមួយៗ គឺសុទ្ធតែទទួលបានជ័យជំនះដ៏ត្រចះត្រចង់សំរាប់ពួកជំនុំ ក្នុងការសំរេចតាមសេចក្តីសន្យានោះទាំងអស់។

ជ័យជំនះទាំង៥នោះរួមគឺមាន៖ ជ័យជំនះលើទឹកជំនន់ ជ័យជំនះលើការឆ្លងកាត់សមុទ្រក្រហម ជ័យជំនះរបស់ស្តេចដាវីឌ ដែលបានឈ្នះលើខ្មាំងសត្រូវទាំងអស់ក្នុងទឹកដីសន្យា ដោយបូករួមនឹងសេចក្តីសុខសាន្ត និងភាពចំរុងចំរើនក្នុងរជ្ជកាលព្រះបាទសាឡូម៉ូនផងដែរ ជ័យជំនះដោយបានរួចពីទាសភាពនិងជ័យជំនះនៃកំណើតរបស់ព្រះយេស៊ូគ្រីស្ទ។ ចំណែកឯជ័យជំនះទី៦វិញ គឺត្រូវបានគេរៀបរាប់នៅក្នុងជីវប្រវត្តិនៃព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ដើម្បីសំដែងពីសិរីរុងរឿងចំពោះការយាងមករបស់ព្រះគ្រីស្ទ នៅថ្ងៃចុងក្រោយបង្អស់ដើម្បីនឹងបានសំរេចបានទៅដល់ថ្ងៃបុណ្យឈប់សំរាក ដ៏នៅអស់កល្បជានិច្ចវិញ។

Copyright © Gratia Dei Sola Media

យើងបានគូសបញ្ជាក់នូវសេចក្តីពិតនៃអត្ថបទគម្ពីរអំពីសម័យកាលនិមួយៗផងដែរថា ចំពោះសម្ព័ន្ធមេត្រីរបស់យើង ព្រះជាម្ចាស់នៅតែស្មោះត្រង់ ចំពោះព្រះបន្ទូលសន្យារបស់ទ្រង់ជានិច្ចបើទោះបីជារឿយៗមានពួកជំនុំរបស់ទ្រង់ខ្លះ បានវែកញែកបរិហារថា ព្រះបន្ទូលសន្យាទាំងនោះគ្មានសេចក្តីពិតយ៉ាងណាក៏ដោយ។

សៀវភៅកិច្ចការត្រូវបានតាក់តែងរចនាឡើង ដើម្បីជួយឲ្យកុមារអាចធ្វើការដោយខ្លួនឯង ដែលមាននៅក្នុងសេចក្តីពិតសំរាប់ឲ្យគេតាំងចិត្តនឹងទន្ទេញឲ្យបានចងចាំ។

យើងប្រាថ្នាចង់ស្គាល់នូវការណែនាំពីជីវប្រវត្តិនៃព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់ របស់លោក Rev. G. M. Ophoff ដែលជាសាស្ត្រាចារ្យផ្នែកខាងទេវសាស្ត្រ នៅក្នុងសាលារបស់ពួកជំនុំកំណែទម្រង់ និកាយប្រូតេសស្តង់នៅសហរដ្ឋអាមេរិក គឺជាការណែនាំមួយ ប្រកបដោយការជំរុញទឹកចិត្តដល់យើង សំរាប់ការចងក្រងសៀវភៅសំនួរចំលើយពីគោលជំនឿ បែបជាលក្ខណៈធម្មជាតិមួយនេះ ហើយបានបង្កើតមូលដ្ឋានជារូបរាងឡើងសម្រាប់ទ្រទ្រង់ដល់ការណែនាំ ដែលមាននៅក្នុងសៀវភៅសំនួរចំលើយនេះ។

សូមឲ្យសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់យើងបានប្រទានពរចំពោះការណែនាំ ដែលបានផ្តល់ជូននូវការប្រើប្រាស់សៀវភៅសំនួរចំលើយនេះ សំរាប់ឲ្យសម្ព័ន្ធមេត្រីយុវជនរបស់យើងរៀនស្រឡាញ់សេចក្តីពិតទាំងអស់នោះ "ដូច្នេះមិនមែនសំរេចនឹង

Copyright © Gratia Dei Sola Media

អ្នកណាដែលចង់បាន ឬនឹងអ្នកណាដែលខំរត់តាមនោះទេគឺស្រេចនឹងព្រះដែលមានសេចក្តីមេត្តាករុណាវិញ”។(រ៉ូម ៩:១៦)

**លោកគ្រូគង្វាល ចន អរ. ហ៊ីស, ១៩៦១**

Copyright © Gratia Dei Sola Media

# អារម្ភកថាអ្នកកែសម្រួល

សៀវភៅនេះ (បោះពុម្ពនៅខែមិថុនា ឆ្នាំ២០០៣) ត្រូវបានបោះពុម្ពផ្សព្វផ្សាយចេញ ពីអ្វីដែលមានក្នុងការប្រើប្រាស់តាមរយៈPRCក្នុងសហរដ្ឋអាមេរិកសំរាប់៩ទស្សវត្សរ៍ចុងក្រោយនេះ។

មានកំហុសខ្លះៗនៃការសរសេរ និងកំហុសផ្សេងៗទៀតត្រូវដកចេញ ហើយមានសំនួរចំលើយខ្លះៗទៀតក៏ត្រូវកែរតំរូវឡើងវិញដែរ ដើម្បីអោយមានភាពងាយស្រួលជាងមុន សំរាប់កុមារបានចងចាំដោយគ្មានភាពស្មុគស្មាញ លើសៀវភៅនេះ។ ខគម្ពីរចងចាំ (មកពី Scottish Psalter) ត្រូវបានដាក់បញ្ចូលទុកសំរាប់ជាអត្ថប្រយោជន៍បន្ថែម ចំពោះអស់អ្នកដែលមិនធ្លាប់ទន្ទេញព្រះគម្ពីរទំនុកដម្កើងនៅឡើយ។

សៀវភៅនេះគឺជាផ្នែកទីបី នៅក្នុងសៀវភៅសំនួរចំលើយនេះ។ មាតាបិតា និងអាណាព្យាបាលជាច្រើនបានកត់សំគាល់ឃើញថា វាបានធ្វើឲ្យមានភាពរីកចំរើនយ៉ាងស៊ីជំរៅ ហើយក៏នៅមានការលំបាកខ្លះៗនៅលាយឡំគ្នានឹងការបង្កើនសមត្ថភាពរបស់កុមារផងដែរ។ ទោះជាយ៉ាងក៏ដោយ មានកុមារមួយចំនួនអាចស្វែងរកឃើញដោយខ្លួនឯង និងអាចធ្វើអោយបានដូចគ្នាជាងមុនទៅនឹងសំនួរទាំង១០ហើយនឹងខគម្ពីរចងចាំ។ ប្រសិនបើមានករណីបែបនេះ ខ្ញុំសូមលើកទឹកចិត្តចំពោះមាតាបិតាទាំងអស់ផ្តល់ឱកាស ឲ្យពួកគេទន្ទេញសារឡើងវិញ Westminster Shorter Catechism ក្នុងការប្រៀបធៀបទៅនឹងកំរិតសិក្សាក្រោយៗបន្ទាប់ទៀត។

Copyright © Gratia Dei Sola Media

សូមព្រះជាម្ចាស់ប្រទានពរដល់ការខិតខំប្រឹងប្រែងដ៏ទន់ខ្សោយរបស់យើង ដើម្បីនាំឲ្យកុមារៗទទួលបានការយកចិត្តទុកដាក់ពីពួកយើង ដោយយោងទៅតាមភាពចាំបាច់នៃសម្ព័ន្ធមេត្រីរបស់យើង។

**លោកគ្រូគង្វាល ជេ. ជេ. លិម, ២០១១**

Copyright © Gratia Dei Sola Media

**Bible History Catechism-Old Testament History**
**(The Unfolding of God's Covenant Promise)**
**(Seniors-Book 1/2)**

By Rev John A heys edited by J.J.Lim
With invaluable contributions by Ps David Higgs

Original version by Rev John A Heys is property of the Protestant Reformed Churches Of America
J.J.Lim edited version ©2011 by Pilgrim Covenant Church.

Khmer Language version © Gratia Dei Sola Media

Published by Gratia Dei Sola Media
Blk 2033b, Henderson Road, #07 -07, Singapore 159546.
Website: www.gdsmedia.org
Email:gdsmedia.sg@gmail.com

All rights reserved  Printed in Singapore

Copyright © Gratia Dei Sola Media

# សម័យកាលទី ១
# ចាប់តាំងពីការបង្កបង្កើតរហូតមកទល់នឹងជ័យជំនះ ក្នុងសម័យកាលទឹកជំនន់

## មេរៀនទី ១
## ព្រះជាម្ចាស់ជាអ្នកបង្កើតអ្វីៗទាំងអស់

**១. ការដកស្រង់ខគម្ពីរដំបូងបង្អស់នៃព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ។**
"កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនិងផែនដី"។
(លោកុប្បត្តិ ១:១)

**២. ហេតុអ្វីទើបព្រះគម្ពីរយើងមានសារៈសំខាន់ ដោយចាប់ផ្តើមពីខគម្ពីរមួយនេះ?**
"ពីព្រោះខនេះបានបង្រៀនយើងថា ព្រះជាម្ចាស់គឺមានតាំងពីអស់កល្បមកម្ល៉េះ ហើយគ្រប់អ្វីៗទាំងអស់ គឺកើតមកដោយសារទ្រង់ ទាំងរបស់មើលឃើញ និងរបស់មើលមិនឃើញ"។
(ទំនុកដំកើង៩០:២)

**៣. តើព្រះជាម្ចាស់បានបង្កើតអ្វីទាំងអស់មកយ៉ាងដូចម្តេច?**
"ត្បិតទ្រង់គ្រាន់តែមានព្រះបន្ទូល នោះក៏កើតមានដូច្នោះ ទ្រង់បង្គាប់នោះក៏មាននៅ"។ (ទំនុកដំកើង ៣៣:៩)

**៤. ហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតគ្រប់អ្វីៗទាំងអស់នោះមក?**
"ព្រះជាម្ចាស់បង្កើតអ្វីៗទាំងអស់មក ដើម្បីជាសិរីល្អដល់ព្រះនាមទ្រង់"។ (វិវរណៈ ៤:១១)


Copyright © Gratia Dei Sola Media

៥. **តើចំណុចសំខាន់អ្វីដែលយើងបានអានពីការបង្កើតមនុស្ស ដំបូងបង្អស់?**
បទគម្ពីរបានអោយយើងដឹងថា "ព្រះជាម្ចាស់បង្កើតមនុស្សមក អោយចំនឹងរូបអង្គទ្រង់"។ (លោកុប្បត្តិ ១:២៧)

៦. **តើមនុស្សត្រូវបានបង្កើតមកដោយមានភាពខុសគ្នាប្លែកពីអ្វីៗ ដែលមាន នៅលើផែនដីមែនឬ ?**
មែនហើយ មនុស្សត្រូវបានបង្កើតមកដូច្នេះ ដើម្បីអោយគេ អាចស្គាល់ទ្រង់ និយាយជាមួយទ្រង់ និងស្រឡាញ់ទ្រង់។ (លោកុប្បត្តិ ២:៧[ខ])

៧. **តើព្រះជាម្ចាស់បានបង្កើតមនុស្សមកយ៉ាងដូចម្តេច?**
"ព្រះយេហូវ៉ាដ៏ជាព្រះ ទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះនោះ ក៏ត្រឡប់ ជាមានព្រលឹងរស់ឡើង"។ (លោកុប្បត្តិ ២:៧)

៨. **តើទំនាក់ទំនងរបស់អ័ដាម ជាមួយនឹងអ្វីៗដែលមាននៅលើ ផែនដីមានលក្ខណៈដូចម្តេច?**
គាត់ គឺជាស្តេចលើអ្វីៗដែលមាននៅលើផែនដី បន្ទាប់ព្រះជា ម្ចាស់។ (លោកុប្បត្តិ ១:២៦, ទំនុកដំកើង ៨:៦-៨)

៩. **តើអ័ដាមបានអាស្រ័យរស់នៅឯណា?**
គាត់បានអាស្រ័យនៅក្នុងសួនច្បារអេដែន ដែលជាទិដ្ឋភាព មួយនៃនរគស្ថានសួគ៌។ (វិវរណៈ ២២:១-២)

១០. **តើដើមឈើអ្វីដែលមាននៅចំកណ្តាលសួនច្បារនោះ?**



Copyright © Gratia Dei Sola Media

គឺដើមជីវិត និងដើមដឹងខុសត្រូវ។(លោកុប្បត្តិ ២:១៧, ៣:២៤)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១៤៥:១-៤) [១]ឱព្រះដ៏ជាមហាក្សត្រនៃទូលបង្គំអើយ ទូលបង្គំនឹងលើដំកើងទ្រង់ ហើយនឹងសូមអោយព្រះនាមទ្រង់បានពរអស់កល្បជានិច្ច [២]ទូលបង្គំនឹងសូមអោយទ្រង់ បានប្រកបដោយព្រះពររាល់ៗថ្ងៃ ព្រមទាំង សរសើរដល់ព្រះនាមទ្រង់អស់កល្បជានិច្ច [៣]ព្រះយេហូវ៉ាធំប្រសើរ គឺគួរសរសើរយ៉ាងក្រៃលែង ឯសណ្ឋានធំប្រសើររបស់ទ្រង់នោះនឹងរកយល់មិនបាន [៤]មនុស្សដំណរមួយនឹងសរសើរស្នាដៃរបស់ផងទ្រង់ ដល់ដំណរមួយទៀតព្រមទាំងប្រកាសប្រាប់ពីការឥទ្ធិឫទ្ធិរបស់ទ្រង់ផង។


Copyright © Gratia Dei Sola Media

# មេរៀនទី ២
# ព្រះបន្ទូលសន្យាពីដំណឹងល្អ

**១. តើព្រះជាម្ចាស់មានព្រះបន្ទូលទៅអ័ដាមដូចម្ដេចខ្លះ ពីដើមដឹងខុសត្រូវ?**

"តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវអោយឯងស៊ីផល ឡើយ ត្បិតថ្ងៃណាដែលឯងស៊ីនោះនឹងត្រូវស្លាប់ជាមិនខាន"។ (លោកុប្បត្តិ ២:១៧)

**២. តើអ័ដាមបានស្ដាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះជាម្ចាស់ឬទេ?**

ទេ! គាត់បានបរិភោគពីផ្លែឈើដឹងខុសត្រូវ ដែលព្រះបាន ហាមព្រោះនាងអេវ៉ាបានប្រគល់អោយគាត់។
(លោកុប្បត្តិ ៣:៦)

**៣. តើនរណាបានមកល្បួងនាងអេវ៉ាអោយបរិភោគពីផ្លែឈើ ដែលព្រះជាម្ចាស់បានហាម?**

គឺសាតាំងបានល្បួងនាងដោយបញ្ឆោទនាងថា "នាងនឹងមិនស្លាប់ជាពិត មែនទេ"។ (លោកុប្បត្តិ ៣:៤-៥)



Copyright © Gratia Dei Sola Media

**៤. តើអ័ដាម និងនាងអេវ៉ា ដឹងថាពួកគេនឹងមានទោសដោយសារអំពើបាបរបស់ពួកគេដែរឬទេ?**

មែនហើយ ពួកគេបានដឹងថាខ្លួននៅអាក្រាត ហើយពួកគេបានយកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់បុឹង។(លោកុប្បត្តិ ៣:៧)

**៥. តើព្រះជាម្ចាស់បានជួយបិទបាំងភាពអាក្រាត របស់ពួកគេយ៉ាងដូចម្តេច?**

ព្រះជាម្ចាស់ក៏ធ្វើអាវពីស្បែក អោយពួកគេពាក់ដើម្បីបិទបាំងកាយ។ (លោកុប្បត្តិ ៣:២១)

**៦. តើព្រះជាម្ចាស់បានដាក់បណ្តាសារដល់សាតាំងដូចម្តេច?**

"អញនឹងធ្វើអោយឯងហើយនឹងស្ត្រី គឺពូជឯងនឹងពូជនាងមានសេចក្តីខ្មាំងនឹងគ្នាពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ"។ (លោកុប្បត្តិ ៣:១៥)

**៧. តើអ្វីទៅដែលជាចំណុចសំខាន់នៅក្នុងអត្ថបទគម្ពីរនេះ ?**

គឺជាការប្រាប់អោយដឹងថា នោះគឺជាព្រះបន្ទូលសន្យាដំបូងបង្អស់អំពីដំណឹងល្អ។

**៨. តើពូជរបស់ស្ត្រីសំដៅលើ កូនចៅទាំងអស់របស់នាងអេវ៉ាមែនទេ?**

ទេ! គឺសំដៅទៅចំពោះព្រះគ្រីស្ទ និងអស់អ្នកដែលបានមករួបរួមក្នុងព្រះអង្គ។ (កាឡាទី៣:១៦, អេភេសូរ៥:៣០,។ល។)



Copyright © Gratia Dei Sola Media

**៩. តើអ្នកណាដែលព្រះជាម្ចាស់ចង់បញ្ជាក់ន័យថា ជាពូជសត្វពស់?**

គឺទ្រង់ចង់មានន័យថា គឺអស់ពួកអ្នកដែលស្អប់ទ្រង់ និងពួកជំនុំទ្រង់ ហើយមានកន្លែងខ្លះក្នុងព្រះគម្ពីរហៅថា "លោកិយ"។ (១យ៉ូហាន ៣:១៣)

**១០.តើព្រះជាម្ចាស់បានសំរេចតាមព្រះបន្ទូលសន្យា របស់ទ្រង់យ៉ាងដូចម្ដេច?**

គឺទ្រង់បានចាត់បញ្ជូនអ្នកសង្គ្រោះ ដើម្បីមកនាំរាស្ត្រទ្រង់អោយចេញពី អំណាចរបស់សាតាំង។ (រ៉ូម ១៦:២០)

**ខគម្ពីរចងចាំបន្ថែម៖** ទំនុកដំកើង ១៤៥:៥-៦ ⁵ទូលបង្គំនឹងរំពឹងគិតពីឫទ្ធានុភាពដ៏រុងរឿងឧត្តម ហើយពីការអស្ចារ្យរបស់ទ្រង់ដែរ ⁶មនុស្សទាំងឡាយនឹងថ្លែងពីឫទ្ធិនៃការដ៏គួរស្ញែងខ្លាចរបស់ទ្រង់ ឯទូលបង្គំនឹងប្រកាសពីសណ្ឋានដ៏ធំវិសេសនៃទ្រង់ដែរ។



Copyright © Gratia Dei Sola Media

# មេរៀនទី ៣
# នាពរីករាលដាលរបស់អំពើបាប

**១. តើអ្វីទៅដែលបានក្លាយមកជារឿងធម្មតា ចំពោះកូនដំបូងទាំងពីរដែល ព្រះជាម្ចាស់បានប្រទានអោយ អ័ដាម និងនាងអេវ៉ា?**
គឺថាកាអ៊ីនមនុស្សកំណាច គឺជាពូជរបស់សត្វពស់ ចំណែកអេបិលជាមនុស្សសុចរិតវិញ គឺជាពូជរបស់ស្ត្រីវិញ ។ (១យ៉ូហាន៣:១២, ម៉ាថាយ ២៣:៣៥)

**២. តើអេបិលបានបង្ហាញថាគាត់គឺជាពូជរបស់ស្ត្រីយ៉ាងដូចម្តេច?**
ដោយសារជំនឿគាត់យកសត្វ មកថ្វាយជាយញ្ញបូជាដល់ព្រះ ដែលបានបញ្ជាក់ពីសក្ខីភាពនៃជំនឿរបស់គាត់ក្នុងព្រះគ្រីស្ត។ (លោកុប្បត្តិ ៤:៤, ហេព្រើរ ១១:៤)

**៣. តើកាអ៊ីនបានបង្ហាញថាគាត់ជាពូជរបស់សត្វពស់ដូចម្តេច?**
គាត់មិនអើពើពីការណែនាំរបស់ព្រះ ថាគួគម្បីថ្វាយបង្គំទ្រង់យ៉ាងណា គាត់បានថ្វាយព្រះនូវផលដុះចេញមកពីដី ហើយគាត់ថែមទាំងបានសំលាប់អេបិល ជាប្អូនដែលស្រឡាញ់ព្រះទៀតផង។ (លោកុប្បត្តិ ៤:៨)

**៤. តើសាតាំងមានគោលបំណងដូចម្តេចក្នុងការសំលាប់អេបិល?**
វាបានខិតខំប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់ ដើម្បីរាំងការចាប់កំណើតរបស់ព្រះគ្រីស្ទ។ (លោកុប្បត្តិ៣:១៥,១យ៉ូហាន ៣:១២)


Copyright © Gratia Dei Sola Media

**៥. តើព្រះជាម្ចាស់នឹងបន្តពូជស្ត្រីទៅមុខយ៉ាងដូចម្ដេច ក្រោយពីមរណៈភាពរបស់អេបិល?**

ព្រះជាម្ចាស់បានប្រទានអោយអ័ដាម និងនាងអេវ៉ាមានកូនប្រុសដែលកោតខ្លាចព្រះម្នាក់ទៀត ដែលអោយឈ្មោះថាសេត។ (លោកុប្បត្តិ ៤:២៥)

**៦. តើការអាក្រក់របស់ពូជសត្វពស់នឹងកើតមានជាថ្មី ម្ដងទៀតដែរឬទេ?**

វាប្រាកដជាកើតមានឡើងជាថ្មីទៀតមិនខាន ការអាក្រក់របស់មនុស្ស មានឥទ្ធិពលយ៉ាងខ្លាំងនៅលើផែនដីនេះ។ (លោកុប្បត្តិ ៦:៥)

**៧. តើឥទ្ធិពលនៃការអាក្រក់របស់មនុស្សយ៉ាងដូចម្ដេច?**

ហើយអស់ទាំងគំនិតក្នុងចិត្តរបស់គេ ក៏សុទ្ធតែអាក្រក់ជានិច្ចដូចច្នេះ។ (លោកុប្បត្តិ ៦:៥)

**៨. ការសំគាល់ពីមនុស្សម្នាក់ ក្នុងចំណោមកូនចៅកាអ៊ីនដែលបង្ហាញអោយឃើញថា គាត់គឺជាពូជពង្សរបស់សត្វពស់។**

មនុស្សអាក្រក់ ឡាមេកដែលបាននិយាយយ៉ាងក្អេងក្អាងទៅប្រពន្ធទាំងពីររបស់គាត់ថាគាត់ត្រូវតែសំឡាប់មនុស្សម្នាក់។ (លោកុប្បត្តិ ៤:២៣)


Copyright © Gratia Dei Sola Media

**៩. ការសំគាល់ពីមនុស្សម្នាក់ ក្នុងចំណោមកូនចៅរបស់សេត ដែលជាពូជពង្សរបស់ស្ត្រី។**

គឺហេណុក ដែលជាអ្នកបានដើរតាមព្រះជាម្ចាស់។ (លោកុប្បត្តិ ៥:២៤)

**១០.តើពូជពង្សនៃដំណររបស់ស្ត្រីបានបំរើព្រះ ដោយកំលាំងគេផ្ទាល់មែនទេ?**

ទេ! "ត្បិតគឺព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នាអោយមានទាំងចំណង់ចង់ធ្វើ ហើយអោយប្រព្រឹត្តតាមបំណងព្រះទ័យទ្រង់ដែរ"។ (ភីលីព ២:១៣)

**ខគម្ពីរចងចាំបន្ថែម៖** ទំនុកដំកើង ១៤៥:៧-៨ [៧]គេនឹងបញ្ចេញសេចក្តីដែលនឹកចាំពី ព្រះហឫទ័យដ៏ល្អប្រសើរ ហើយច្រៀងពីសេចក្តីសុចរិតរបស់ទ្រង់ [៨]ព្រះយេហូវ៉ាទ្រង់ប្រកបដោយដោយមេត្តាករុណា និងអាណិតអាសូរ ទ្រង់យឺតនឹងខ្ញាល់ក៏មានសេចក្តីសប្បុរសដ៏ធំទូលាយ។



Copyright © Gratia Dei Sola Media

# មេរៀនទី ៤
# សេចក្ដីសង្គ្រោះនៅក្នុងទូកធំ

**១. តើមានពួកជំនុំមានគ្នាច្រើន នៅក្នុងសម័យកាលទឹកជំនន់ទេ?**
ទេ! គឺមានតែព្រលឹងមនុស្សនៅរស់ត្រឹមតែប្រាំបីនាក់ប៉ុណ្ណោះ គឺជាអ្នកដែលជឿ និងស្ដាប់បង្គាប់តាមព្រះជាម្ចាស់។ (១ ពេត្រុស ៣:២០)

**២. តើលោកណូអេបង្ហាញពីជំនឿរបស់គាត់ដល់អ្នក ដែលមិនព្រមជឿតាមពាក្យគាត់យ៉ាងដូចម្ដេច?**
គឺគាត់បង្ហាញពីជំនឿរបស់គាត់ ដោយការសាងសង់ទូកធំមួយតាមដែលព្រះជាម្ចាស់បានបង្គាប់។ (ហេព្រើរ ១១:៧)

**៣. តើយើងអានអ្វីខ្លះដែលស្ដីពីអំពើអាក្រក់នៃផែនដី នៅក្នុងថ្ងៃនោះ?**
ពួកគេរស់ក្នុងអំពើបាប ហើយទាំងបានប្រព្រឹត្តអំពើបាបថែមទៀតផង ដោយពួកគេនឹកស្មានថាគ្មានទឹកជំនន់ឡើយ។ (ម៉ាថាយ ២៤:៣៧-៣៩)


Copyright © Gratia Dei Sola Media

## ៤. តើព្រះជាម្ចាស់ ធ្វើយ៉ាងដូចម្ដេចសំរាប់ពួកជំនុំរបស់ទ្រង់នៅក្នុងថ្ងៃនោះ?

ព្រះជាម្ចាស់បានសង្គ្រោះពួកជំនុំរបស់ទ្រង់ អោយរួចផុតពីភាពស្មោគគ្រោកដ៏អាក្រក់របស់ផែនដី ដោយសារទឹកជំនន់។ (១ ពេត្រុស ៣:២០)

## ៥. តើមានព្រះបន្ទូលសន្យាដ៏អស្ចារ្យបែបណា ដែលព្រះជាម្ចាស់បានប្រទានដល់លោកណូអេ?

ព្រះជាម្ចាស់បានមានព្រះបន្ទូលទៅលោកណូអេថា "តែអញនឹងតាំងសេចក្ដីសញ្ញាអញចំពោះឯង"។ (លោកុប្បត្តិ ៦:១៨)

## ៦. តើព្រះបន្ទូលសន្យានេះមានអត្ថន័យយ៉ាងដូចម្ដេច?

មានន័យថា ព្រះជាម្ចាស់សព្វព្រះហប្ញទ័យចងមិត្តភាពជាមួយគាត់ថែមទាំងសង្គ្រោះគាត់ និងក្រុមគ្រួសាររបស់គាត់ដោយសារទូកធំទៀតផង។ (១ពេត្រុស ៣:២០; ហេព្រើ ១១:៦-៧)

## ៧. តើព្រះជាម្ចាស់គោរពតាមព្រះបន្ទូលសន្យារបស់ព្រះអង្គឬទេ?

ពិតមែន ដោយព្រះជាម្ចាស់បានបំផ្លាញរាល់ភាពស្មោគគ្រោកដ៏អាក្រក់របស់ផែនដីដោយសារទឹកជំនន់ តែទ្រង់បានសង្គ្រោះលោកណូអេ និងក្រុមគ្រួសាររបស់គាត់វិញ។ (លោកុប្បត្តិ ៧:២១-២៣)



Copyright © Gratia Dei Sola Media

**៨. តើនៅមានព្រះបន្ទូលសន្យាអ្វីខ្លះទៀត?**

គឺថាព្រះជាម្ចាស់សព្វព្រះហប្ញទ័យ សង្គ្រោះពួកជំនុំរបស់ទ្រង់ តាមរយៈ អ្នកសង្គ្រោះដែលទ្រង់សព្វព្រះហប្ញទ័យចាត់មក។ (១ពេត្រុស៣:២០-២១, ម៉ាថាយ ១:២១, ១កូរិថូស ១២:១២-១៣)

**៩. ហេតុអ្វីបានជាវិនាសកម្ម នៃការបំផ្លាញភាពស្មោគគ្រោកដ៏អាក្រក់នេះមានសារៈសំខាន់ដល់ម្លេះ?**

ពីព្រោះវាគឺជាការដោះលែងដ៏អស្ចារ្យដំបូងបង្អស់ ដែលព្រះជាម្ចាស់ប្រទានអោយពួកជំនុំរបស់ទ្រង់។(លោកុប្បត្តិ ៣:១៥)

**១០.តើនៅមានអ្វីផ្សេងទៀត ដែលអាចបរិយាយអំពីវិនាសកម្មនៃការបំផ្លាញភាពស្មោគគ្រោករបស់ផែនដីដ៏អាក្រក់នេះ?**

វាគឺជាសណ្ឋានមួយនៃការជំនុំជំរះ លើកចុងក្រោយបង្អស់នៃលោកិយនេះ។ (ម៉ាថាយ ២៤:៣៧-៣៩)

**ខគម្ពីរចងចាំបន្ថែម៖** ទំនុកដំកើង ១៤៥:៩ ព្រះយេហូវ៉ាទ្រង់ល្អដល់មនុស្សទាំងអស់ ហើយព្រះទ័យទន់សន្ដោសរបស់ទ្រង់ក៏គ្របលើកិច្ចការរបស់ទ្រង់ទាំងប៉ុន្មាន។



Copyright © Gratia Dei Sola Media

# សម័យកាលទី ២
# ចាប់តាំងពីក្រោយពេលទឹកជំនន់រហូតមកទល់នឹងជ័យជំនះ ក្នុងការឆ្លងកាត់សមុទ្រក្រហម

## មេរៀនទី ៥
## ការបង្ហាញខ្លួនជាថ្មីម្តងទៀតរបស់អំពើបាប

**១. តើអំពើបាបបានបង្ហាញខ្លួនវាយ៉ាងដូចម្តេច ក្រោយទឹកជំនន់?**
គឺលោកណូអេស្រវឹងស្រា ហើយហាំមានចិត្តត្រេកអរនឹងអំពើបាបរបស់ឪពុករបស់គាត់។ (លោកុប្បត្តិ ៩:២០-២២)

**២. តើព្រះជាម្ចាស់ បានបង្ហាញយើងពីអំពើបាបរបស់អស់អ្នកដែលទ្រង់សង្គ្រោះអោយរួចផុតពីទឹកជំនន់យ៉ាងដូចម្តេច?**
ទ្រង់បង្ហាញអោយយើងដឹងថា ទឹកជំនន់មិនមែនជាជ័យជំនះលើអំពើបាបចុងក្រោយនោះឡើយ។
(ហេព្រើ ១១:៧, រ៉ូម ៣:២១-២៦)

**៣. តើពួកគេមានអារម្មណ៍ដឹងថាត្រូវការជំរូវការដ៏ចាំបាច់បែបណាចំពោះអំពើបាបរបស់ពួកគេ?**
គឺពួកគេដឹងថា គេត្រូវការអ្នកសង្គ្រោះ ដើម្បីរំដោះគេអោយរួចពីបាប។ (ហេព្រើ១១:១៣)


Copyright © Gratia Dei Sola Media

៤. **តើសិម និងយ៉ាផែតបានបង្ហាញពីភាពសុច្ចរិតរបស់ខ្លួនយ៉ាងដូចម្ដេច?**

ដោយបង្ហាញពីការសោកស្ដាយ ក្នុងការដែលពួកគាត់ប្រព្រឹត្តអំពើបាបប៉ុន្តែពួកគាត់បានគ្របបាំងភាពអាក្រាតឪពុកគាត់។ (លោកុប្បត្តិ ៩:២៤-២៧)

៥. **តើមានអ្វីដែលបង្ហាញថា លោកណូអេស្អប់ខ្ពើមអំពើបាបដែលគាត់ធ្វើ?**

មែនហើយ គឺក្រោយគាត់ប្រទានពរអោយសិម និងយ៉ាផែតតែដាក់បណ្ដាសារដល់កាណានដែលជាកូនប្រុសរបស់ហាំ។ (លោកុប្បត្តិ ៩:២៤-២៧)

៦. **ក្រោយពីទឹកជំនន់មក តើអំពើបាបចំរើនឡើងយ៉ាងឆាប់រហ័សមែនទេ?**

ជាការពិតណាស់ គឺការអាក្រក់របស់ផែនដី បានបះបោរប្រឆាំងនឹងព្រះ យ៉ាងរហ័សតាមរយៈកាសង់ប៉មបាបិល។ (លោកុប្បត្តិ១១:១-៤)

៧. **ហេតុអ្វីបានជាមនុស្សអាក្រក់នៅលើផែនដី នាំគ្នាសង់ប៉មនោះឡើង?**

ដោយសារពួកគេចង់តាំងលំនៅ ជាមួយគ្នាដែលជាទីក្រុងមួយដ៏រឹងមាំ។ (លោកុប្បត្តិ ១១:៤)



Copyright © Gratia Dei Sola Media

**៨. តើព្រះជាម្ចាស់ទប់ស្កាត់ផែនការណ៍នេះយ៉ាងដូចម្ដេច?**

គឺព្រះជាម្ចាស់បានបំភាន់ភាសាពួកគេ ដើម្បីអោយពួកគេបែកខ្ញែកគ្នាទៅពាសពេញផែនដីវិញ។ (លោកុប្បត្តិ ១១:៧-៨)

**៩. ហេតុអ្វីព្រះកំចាត់កំចាយ ហើយញែកពួកគេជាសាសន៍ផ្សេងៗបែបនេះ?**

គឺដើម្បីអោយពួកជំនុំរបស់ព្រះអង្គរីកចំរើនដោយសុខសាន្តនៅលើផែនដីដ៏ស្មោគគ្រោកនេះ។ (លោកុប្បត្តិ ១២:១-៣)

**១០.តើយើងអាចរកឃើញការចងសម្ព័ន្ធមេត្រីនៃព្រះជាមួយមនុស្សលោកតាំងពីពេលនោះមកនៅឯណា?**

ពួកជំនុំអាចស្វែងរកឃើញការចងសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ជាមួយមនុស្សលោក តាមរយៈកូនចៅសិម ហើយក្រោយមកទៀតក៏ឃើញតាម រយៈកូនចៅរបស់ យ៉ាផែតផងដែរ។ (លោកុប្បត្តិ ៩:២៦-២៧)

**ខគម្ពីរចងចាំបន្ថែម៖** ទំនុកដំកើង ១៤៥:១០-១២ [១០]ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់នឹងអរព្រះគុណដល់ទ្រង់ ហើយនិងពួកអ្នកបរិសុទ្ធរបស់ទ្រង់ នឹងសូមអោយទ្រង់បានប្រកបដោយព្រះពរ [១១]គេនឹងថ្លែងពីសិរីល្អនៃនគរទ្រង់នឹងពីតេជានុភាពរបស់ទ្រង់ [១២]ប្រយោជន៍អោយពួកមនុស្សជាតិបានស្គាល់អស់ទាំងការឥទ្ធិឫទ្ធិរបស់ទ្រង់ ហើយនឹងសិរីល្អនៃឫទ្ធានុភាពរបស់រាជ្យទ្រង់ ។



Copyright © Gratia Dei Sola Media

# មេរៀនទី ៦
# ការត្រាស់ហៅលោក អ័ប្រាហាំ

**១. ហេតុអ្វីបានជាព្រះជាម្ចាស់ត្រាស់ហៅលោកអ័ប្រាហាំ អោយចាកចេញពីស្រុកទេស និងញាតិសន្តានរបស់គាត់?**

គឺដើម្បីបន្តសម្ព័ន្ធមេត្រីភាពរបស់ព្រះអង្គ ហើយនឹងពូជពង្សរបស់ទ្រង់នៅក្នុងទឹកដីសន្យា។ (លោកុប្បត្តិ ១២:១)

**២. ហេតុនេះហើយទើបព្រះជាម្ចាស់មានព្រះបន្ទូលពីសេចក្តីសន្យានៃសម្ព័ន្ធមេត្រីតាមរយៈលោកណូអេមែនទេ?**

មែនហើយ តាមរយៈលោកអ័ប្រាហាំដែលជាដំណរកូនចៅរបស់សិម ។ (លោកុប្បត្តិ ៩:២៦, ១១:១១-២៥)

**៣. តើសាសន៍កាណានជាប្រជារាស្ត្រ ដែលគោរពកោតខ្លាចព្រះដែរឬទេ?**

ទេ! ពួកគេជាមនុស្សអាក្រក់ដែលជាដំណរកូនចៅរបស់ហាំ។ (លោកុប្បត្តិ ១០:១-២០)

**៤. បើដូច្នេះ ហេតុអ្វីបានជាព្រះជាម្ចាស់ចាត់លោកអ័ប្រាហាំអោយទៅកាន់ទឹកដីដែលពោរពេញមនុស្សអាក្រក់បែបនេះ?**

ពីព្រោះព្រះអង្គសព្វព្រះហឫទ័យ អោយគាត់ក្លាយទៅជាមនុស្សចំលែកក្នុងទឹកដីសន្យានោះ។ (លោកុប្បត្តិ ១២:៦-៧,១០, ហេព្រើរ ១១:៨-១០)



Copyright © Gratia Dei Sola Media

**៥. ហេតុអ្វីបានព្រះជាម្ចាស់សព្វព្រះហប្ញទ័យអោយលោកអ័ប្រាហាំ ក្លាយជាមនុស្សចំលែកនៅក្នុងទឹកដីសន្យានោះទៅវិញ?**

ពីព្រោះទីនោះគឺជាទឹកដីសន្យាដែលបានបំរុងទុក ជាសណ្ឋាននៃមរតកដ៏អស់កល្បក្នុងអង្គព្រះគ្រីស្ទដែល លោកអ័ប្រាហាំមិនបានកាន់កាប់ពេញ លេញរហូតមកទល់នឹងពេលវេលាកំណត់។ (ហេព្រើរ ១០:១៥-១៦)

**៦. តើលោកអ័ប្រាហាំបាន បើកសំដែលអំពីជំនឿរបស់គាត់ក្នុងព្រះបន្ទូលសន្យានេះយ៉ាងដូចម្តេច?**

គឺគាត់បានបដិសេធន៍មិនព្រមចងសម្ព័ន្ធមិត្តជាមួយនឹងសាសន៍កាណាន ដ៏អាក្រក់នោះឡើយ។ (ហេព្រើរ ១១:៩)

**៧. តើលោកអ័ប្រាហាំបង្ហាញថា គាត់មិនបានទុកចិត្តលើសេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់ជាប់ជានិច្ចយ៉ាងដូចម្តេច?**

គឺគាត់បាននិយាយកុហកពីរដងអំពីភរិយារបស់គាត់ដើម្បីការពារខ្លួន។ (លោកុប្បត្តិ ១២:១០-១៣, ២០:១-២)

**៨. តើលោកអ័ប្រាហាំមានកូនប្រុសម្នាក់ ដែលស្របតាមព្រះបន្ទូលសន្យាដែរឬទេ?**

មែនហើយ ព្រះជាម្ចាស់បានប្រទានកូនប្រុសម្នាក់ដល់លោកអ័ប្រាហាំ និងនាងសារ៉ា ក្នុងកាលដែលគាត់ទាំងពីរមានវ័យចំណាស់ទៅហើយ។ (លោកុប្បត្តិ ២១:១-៥)


Copyright © Gratia Dei Sola Media

**៩. ហេតុអ្វីព្រះទុកអោយលោកអ័ប្រាហាំរង់ចាំកិច្ចសន្យាពីកូនប្រុសរយៈយូរម្លេះ?**

គឺដើម្បីបង្ហាញអោយឃើញថា ការចាប់កំណើតរបស់អ៊ីសាក គឺជាព្រះគុណដ៏សែនអស្ចារ្យមួយ។
(រ៉ូម ៩:៦-៩, ហេព្រើរ ១១:១១-១២)

**១០. តើព្រះជាម្ចាស់មានព្រះបន្ទូលដូចម្តេច ទាក់ទិនកំណើតរបស់អ៊ីសាក?**

"តាមរយៈអ៊ីសាក នឹងបានទៅជាពូជជ្រើសតាំងវិញ"។
(លោកុប្បត្តិ ២១:១២)

**ខគម្ពីរចងចាំបន្ថែម៖** ទំនុកដំកើង ១៤៥:១៣-១៦ [១៣]រាជ្យទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ច ហើយអំណាចទ្រង់ក៏នៅដរាបដល់អស់ទាំងដំណាតទៅ [១៤]ព្រះយេហូវ៉ាងទ្រង់គាំទ្រដល់អស់អ្នកដែលដួល ក៏លើកពួកអ្នកដែលត្រូវឱនឡើងវិញ [១៥]ភ្នែករបស់មនុស្សទាំងអស់ រង់ចាំតែទ្រង់ ហើយទ្រង់ក៏ប្រទានអាហារដល់គេតាមត្រូវពេល [១៦]ទ្រង់លាព្រះហស្ត ក៏បំពេញចិត្តប្រាថ្នានៃជីវិតទាំងឡាយ។



Copyright © Gratia Dei Sola Media

# មេរៀនទី ៧
# សម្ព័ន្ធមេត្រីភាពដែលបានចងឡើងជាមួយនឹងលោកអ័ប្រាហាំ

**១. តើព្រះប្រទានអ្វីខ្លះដល់លោកអ័ប្រាហាំ តាមរយៈសម្ព័ន្ធមេត្រីដែលចងឡើងនេះ?**
គឺព្រះបានធ្វើអោយគាត់ត្រឡប់ជាបិតានៃអ្នកជឿទាំងអស់។ (រ៉ូម ៤:១២)

**២. តើព្រះបើកសំដែងអោយលោកឃើញថា គាត់ជាបិតានៃអ្នកជឿយ៉ាងណា?**
គឺពូជពង្សគាត់មានសន្ធឹកសន្ធាប់ ដូចជាខ្សាច់នៅមាត់សមុទ្រ។ (លោកុប្បត្តិ ២២:១៧)

**៣. តើនរណាដែលជាពូជពង្សនេះ?**
គឺមានព្រះគ្រីស្ទ និងអស់អ្នកដែលជាមនុស្សរបស់ទ្រង់តាមរយៈជំនឿ។ (កាឡាទី ៣:១៦, ១កូរិនថូស ៣:២៣)

**៤. តើព្រះជាម្ចាស់បានល្បងពីជំនឿរបស់លោកអ័ប្រាហាំដូចម្ដេចតាមរយៈព្រះបន្ទូលសន្យានេះ?**
ព្រះជាម្ចាស់បានបង្គាប់អោយគាត់យកអ៊ីសាកកូនប្រុសតែមួយគត់របស់គាត់ទៅថ្វាយជាដង្វាយដុតសំរាប់ព្រះអង្គ។ (លោកុប្បត្តិ ២២:១-២)


Copyright © Gratia Dei Sola Media

**៥. តើលោកអ័ប្រាហាំបានបើកសំដែងពីជំនឿដ៏រឹងមាំរបស់គាត់យ៉ាងដូចម្តេច?**

គាត់បានជឿថាព្រះជាម្ចាស់ប្រាកដជាប្រោសអ៊ីសាកអោយមានជីវិតវិញជាក់ជាមិនខានឡើយ។ (ហេព្រើរ ១១:១៧-១៩)

**៦. តើព្រះជាម្ចាស់បានបង្រៀនលោកអ័ប្រាហាំ តាមរយៈការល្បងលជំនឿរបស់គាត់នេះយ៉ាងដូចម្តេច?**

ព្រះជាម្ចាស់នឹងប្រទានព្រះគ្រីស្ត
អោយយាងមកទុកជាកូនចៀម សំរាប់ប្រជារាស្ត្ររបស់ទ្រង់។
(លោកុប្បត្តិ ២២:១៣-១៤, យ៉ូហាន ១:២៩)

**៧. តើព្រះជាម្ចាស់បានប្រទានសេចក្តីសញ្ញាបែបណា ដល់លោកអ័ប្រាហាំ និងពូជពង្សទាំងអស់របស់គាត់?**

គឺសេចក្តីសញ្ញាដោយការកាត់ស្បែក ដែលបច្ចុប្បន្ននេះត្រូវបានជំនួស ដោយពិធីជ្រមុជទឹកវិញ។(លោកុប្បត្តិ ១៧:៩-១៤)

**៨. តើសារ៉ា ចង់អោយអ៊ីសាកទទួលបានព្រះពរពីសម្ព័ន្ធមេត្រីនេះយ៉ាងណា?**

នាងបានបង្គាប់អោយបណ្តេញអ៊ីស្មាអែលចេញទៅឆ្ងាយ។
(លោកុប្បត្តិ ២១:៩-១០)



Copyright © Gratia Dei Sola Media

**៩. ហេតុអ្វីអ័ប្រាហាំ ចាត់បាវបំរើគាត់អោយរកប្រពន្ធអោយអ៊ីសាក ពីស្រុកខារ៉ាន?**

ពីព្រោះគាត់ចង់ស្វែងរកប្រពន្ធម្នាក់ ដែលគោរពកោតខ្លាច ដល់ព្រះ។ (លោកុប្បត្តិ ២៤:៣-៤)

**១០.តើព្រះជាម្ចាស់បើកសំដែងពីហេតុការណ៍ ដែលត្រូវកើតឡើង អោយពូជពង្សរបស់អ័ប្រាហាំ ដឹងមុនពេលពួកគេទទួលបាន ទឹកដីសន្យាយ៉ាងណា?**

ព្រះជាម្ចាស់បានប្រាប់អ័ប្រាហាំថា ពូជពង្សរបស់គាត់នឹងត្រូវ រងការសង្កត់សង្កិនរយៈពេល ៤០០ឆ្នាំ ក្នុងទឹកដីរបស់សាសន៍ ដទៃ។ (លោកុប្បត្តិ ១៥:១៣)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង១៤៥:១៧-១៩) [១៧]ព្រះ យេហូវ៉ាទ្រង់សុចរិតក្នុងគ្រប់ផ្លូវទ្រង់ ក៏សប្បុរសក្នុងគ្រប់ទាំង កិច្ចការរបស់ទ្រង់ដែរ [១៨]ព្រះយេហូវ៉ាទ្រង់គង់នៅជិត នឹងអស់អ្នកដែលអំពាវនាវដល់ទ្រង់ គឺអស់អ្នកដែលអំពាវនាវដល់ ទ្រង់ដោយពិតត្រង់ [១៩]ទ្រង់នឹងបំពេញបំណងចិត្តនៃអស់អ្នក ដែលកោតខ្លាចដល់ទ្រង់ ក៏នឹងឮពាក្យអំពាវនាវរបស់គេព្រម ទាំងជួយសង្គ្រោះគេផង។



Copyright © Gratia Dei Sola Media

# មេរៀនទី ៨
# សម្ព័ន្ធមេត្រីរបស់មនុស្សលោកចេះតែចំរើនឡើង

**១. តើកូនចៅដែលបានកើតមកជំនាន់ក្រោយទាំងអស់ ក្នុងសម្ព័ន្ធមេត្រីនេះ គឺសុទ្ធតែជាកូនចៅនៃសេចក្ដីសន្យាឬជាកូនចៅនៃពូជជ្រើសតាំងរបស់ព្រះមែនទេ?**
ទេ! ព្រោះព្រះជាម្ចាស់បានបង្ហាញអោយយើងដឹងតាមរយៈកូនប្រុសភ្លោះទាំងពីររបស់អ៊ីសាក និងរេបេកាថាមិនមែនដូច្នោះឡើយ។ (រ៉ូម ៩:១៣)

**២. តើនៅក្នុងព្រះគម្ពីរ រ៉ូម៩:១៣ ព្រះជាម្ចាស់បានប្រកាសប្រាប់ពីកូនប្រុសភ្លោះទាំងពីររបស់អ៊ីសាកយ៉ាងដូចម្ដេចខ្លះ?**
"អញបានស្រឡាញ់យ៉ាកុប តែស្អប់អេសាវវិញ"

**៣. តើយ៉ាកុបបានទទួលយកព្រះពរកូនច្បងបានដូចម្ដេច?**
ដោយសារគាត់បានបន្លំឪពុករបស់គាត់ដែលងងឹតភ្នែកមើលមិនឃើញ។ (លោកុប្បត្តិ ២៧)

**៤. ហេតុអ្វីបានជាការនេះជាការខុសឆ្គង?**
ព្រោះបានបង្ហាញអោយឃើញថា គាត់គ្មានការទុកចិត្តចំពោះព្រះជាម្ចាស់ទាល់តែសោះ។ (ទំនុកដំកើង៣៧:៣)



Copyright © Gratia Dei Sola Media

**៥. តើអេសាវបានធ្វើដូចម្ដេច បន្ទាប់ពីយ៉ាកុបបានទទួលយក ព្រះពរកូនច្បងរួចហើយ?**

គាត់បានរៀបចំផែនការណ៍ ដើម្បីសំឡាប់យ៉ាកុបជាប្អូនចោល នៅថ្ងៃកាន់ទុក្ខឪពុករបស់គាត់។ (លោកុប្បត្តិ ២៧:៤១)

**៦. តើព្រះជាម្ចាស់បានសន្យានឹងយ៉ាកុប ក្នុងសុបិន្តដូចម្ដេចនៅពេលដែលគាត់បានរត់គេចចេញពីកំហឹងរបស់អេសាវ?**

គឺព្រះអង្គនឹងថែរក្សាគាត់ក្នុងស្រុកខារ៉ាន ហើយទ្រង់នឹងនាំគាត់ត្រឡប់មកទឹកដីសន្យាវិញ។ (លោកុប្បត្តិ ២៨:១៣-១៥)

**៧. តើព្រះជាម្ចាស់បានរក្សាព្រះបន្ទូលសន្យា នៃសម្ព័ន្ធមេត្រីជាមួយនឹងយ៉ាកុបយ៉ាងដូចម្ដេច?**

ដោយព្រះជាម្ចាស់បានប្រទានអោយគាត់ មានគ្រួសារមួយ ហើយថែមទាំងមានទ្រព្យសម្បត្តិដ៏ច្រើនទៀតផង។ (លោកុប្បត្តិ ៣០)

**៨. តើព្រះជាម្ចាស់បានធានាអះអាងថានឹងបន្តព្រះពរ ដល់យ៉ាកុបយ៉ាងដូម្ដេចខ្លះ នៅពេលដែលគាត់បានត្រឡប់មកកាន់ទឹកដីស្រុកកាណានវិញ?**

ព្រះប្រាប់ទៅយ៉ាកុបថា ព្រះបន្ទូលសន្យានៃសម្ព័ន្ធមេត្រីនេះ នឹងត្រូវសំរេចដល់គាត់ និងកូនចៅរបស់គាត់ដែរ។ (លោកុប្បត្តិ ២៨:១៣-១៥)



Copyright © Gratia Dei Sola Media

**៩. តើព្រះជាម្ចាស់បានប្រទានកូនប្រុសប៉ុន្មាននាក់ដល់យ៉ាកុប?**

ព្រះជាម្ចាស់បានប្រទានកូនប្រុស១២នាក់ដល់យ៉ាកុប ដែលជាឈ្មោះកុលសម្ព័ន្ធទាំង១២ក្នុងប្រទេសអ៊ីស្រាអែល។ (លោកុប្បត្តិ ៣៥:២២-២៦)

**១០.តើអ្វីខ្លះដែលបានក្លាយមកជាភាពប្រក្រតី ចំពោះជីវិតកូនៗយ៉ាកុប?**

គឺព្រះជាម្ចាស់បានបង្ហាញអោយឃើញពីភាពស្មោះត្រង់របស់ទ្រង់ តាមរយៈសេចក្តីក្រោធខឹងនៃអំពើបាបរបស់ពួកគេ។

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង១៤៥:២០-២១) [២០]ព្រះយេហូវ៉ាទ្រង់រមែងការពារអស់អ្នកដែលស្រឡាញ់ទ្រង់ តែនឹងបំផ្លាញពួកមនុស្សអាក្រក់វិញ [២១]មាត់ទូលបង្គំនឹងពោលពាក្យសរសើរពីព្រះយេហូវ៉ា គួរអោយមនុស្សទាំងឡាយបានសូមអោយ ព្រះនាមបរិសុទ្ធ របស់ទ្រង់បានពរនៅអស់កល្បជានិច្ចដែរ ។



Copyright © Gratia Dei Sola Media

# មេរៀនទី ៩
# សម្ព័នមេត្រីរបស់មនុស្សលោកក្រោមទាសភាពរបស់អេស៊ីព្ទ

**១. តើអំពើអាក្រក់បែបណាដែលកូនប្រុសទាំង១០របស់យ៉ាកុប ប្រព្រឹត្ត?**

ពួកគេបានលក់យ៉ូសែបអោយទៅធ្វើជាទាសករនៅក្នុង ប្រទេសអេស៊ីព្ទ(លោកុប្បត្តិ ៣៧:២៧-៣២)

**២. តើព្រះជាម្ចាស់មានបំណងព្រះហឫទ័យនាំយក នូវការអាក្រក់ដាក់លើជីវិតយ៉ូសែបមែនទេ?**

ទេ! គឺបងប្អូនប្រុសទាំងនោះនាំគ្នាប្រព្រឹត្តការអាក្រក់ ប៉ុន្តែព្រះជាអ្នកប្រព្រឹត្តការល្អវិញ។ (លោកុប្បត្តិ ៥០:២០)

**៣. តើព្រះសំដែងសេចក្តីមេត្តាករុណាចំពោះយ៉ូសែប នៅអេស៊ីព្ទ យ៉ាងណា?**

ព្រះជាម្ចាស់បានលើកគាត់ចេញពីឋានៈជាទាសករ និងពីឋានៈជាដែលអ្នកជាប់ព័ន្ធនាគារ អោយមកធ្វើជាអ្នកគ្រប់គ្រង ប្រទេសអេស៊ីព្ទវិញ។ (លោកុប្ប ត្តិ ៤១:៣៩-៤៤)



Copyright © Gratia Dei Sola Media

**៤. តើកូនប្រុសទាំង១០នាក់យ៉ាកុប បានបង្ហាញអាកប្បកិរិយា ខុសពីមុនចំពោះយ៉ូសែបក្នុងជីវិតមួយក្រោយមកមែនទេ?**

មែនហើយ គឺពួកគេបានផ្លាស់ប្តូរអាកប្បកិរិយា ពេលដែលពួកគេបានសារភាពអំពើបាបរបស់ខ្លួនចំពោះយ៉ូសែបជាប្អូន។ (លោកុប្បត្តិ ៤៤:១៨)

**៥. តើយ៉ាកុបធ្វើដូចម្តេច ពេលដែលគាត់ដឹងថាយ៉ូសែបនៅមានជីវិតរស់?**

ពេលនោះព្រះជាម្ចាស់សព្វព្រះហប្ញទ័យអោយយ៉ាកុប និងក្រុមគ្រួសារទាំងមូលផ្លាស់ទីលំនៅទៅប្រទេសអេស៊ីព្ទវិញ។ (លោកុប្បត្តិ ៤៦:១-៧)

**៦. ហេតុអ្វីទើបព្រះនាំយ៉ាកុប និងគ្រួសារគាត់ទៅរស់នៅប្រទេសអេស៊ីប?**

ពីព្រោះទ្រង់សព្វព្រះហប្ញទ័យបង្ហាញសិរីល្អរបស់ទ្រង់ ក្នុងការរំដោះប្រជារាស្ត្រព្រះអង្គចេញពីនឹមត្រួតត្រា ក្នុងទាសភាពដ៏កំណាចឃោរឃៅរបស់ប្រទេសអេស៊ីព្ទ។ (លោកុប្បត្តិ ៤៨:២១, ៥០:២៤, កិច្ចការ ៧:៦-៧)

**៧. តើព្រះធ្វើអោយទាសភាពកំណាចឃោរឃៅកើតឡើងដូចម្តេច?**

ទ្រង់លើកស្តេចកំណាមួយអង្គអោយឡើងសោយរាជ្យ គឺជាស្តេច ដែលធ្វើអោយប្រជារាស្ត្រអ៊ីស្រាអែលក្លាយទៅជាទាសករ។ (និក្ខមនំ ១:៨-១៤)



Copyright © Gratia Dei Sola Media

**៨. តើភាពជាទាសករនោះមានរូបភាពយ៉ាងដូចម្តេច?**
គឺភាពជាទាសករនៃអំពើបាបខាងព្រលឹងវិញ្ញាណ។
(លូកា១:៧៤-៧៥, លេវីវិន័យ១១:៤៤-៤៥)

**៩. តើនៅមានអ្វីផ្សេងទៀតដែលព្រះបង្រៀនប្រជារាស្ត្ររបស់ទ្រង់តាមរយៈភាពជាទាសករនេះ?**
ទ្រង់បង្រៀនអោយពួកគេបានដឹងថា សេចក្តីសន្យាសម្ព័ន្ធមេត្រីគឺ ដោយសារតែព្រះគុណដ៏អស្ចារ្យរបស់ទ្រង់ប៉ុណ្ណោះ។
(លោកុប្បត្តិ១៧:៧, រ៉ូម៣:២៩ ,១ពេត្រុស១:១៥-២៥)

**១០.តើអ្វីទៅដែលធ្វើអោយប្រជារាស្ត្រអ៊ីស្រាអែលមានសេចក្តីសង្ឃឹមពីការរងទុក្ខវេទនារបស់ពួកគេ?**
ព្រះបានសន្យាថា នឹងនាំពួកគេពីប្រទេសអេស៊ីព្ទអោយត្រឡប់ទៅឯទឹកដីកាណានវិញ។ (លោកុប្បត្តិ ១៥:១៣-១៤)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង១០៥:១-៣) [១]ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ហើយអំពាវនាវដល់ព្រះនាមទ្រង់ ចូរសំដែងពីអស់ទាំងការរបស់ទ្រង់ នៅចំកណ្តាលសាសន៍ទាំងប៉ុន្មាន [២]ចូរច្រៀងថ្វាយទ្រង់ ចូរច្រៀងសរសើរដល់ទ្រង់ចុះ អោយគិតរំពឹងពីអស់ទាំងការអស្ចារ្យរបស់ទ្រង់ [៣]ចូរយកព្រះនាមបរិសុទ្ធរបស់ទ្រង់ជាទីអំណរព្រើព្រួចចុះ ត្រូវអោយអស់អ្នកដែលស្វែងរកព្រះយេហូវ៉ាមានចិត្តរីករាយឡើង។


Copyright © Gratia Dei Sola Media

# មេរៀនទី ១០
# ចាប់តាំងពីការរំដោះប្រជារាស្ត្រអ៊ីស្រាអែល រហូតមកដល់និងសមុទ្រក្រហម

**១. តើព្រះរៀបចំអោយនរណារំដោះសាសន៍អ៊ីស្រាអែលចេញពីអេស៊ីព្ទ?**
ទ្រង់បញ្ជូនលោកម៉ូសេ ដើម្បីបំពេញកិច្ចការនេះ។ (និក្ខមនំ ២ និង ៣)

**២. តើព្រះគ្រីស្ទរៀបចំគាត់យ៉ាងដូចម្តេច ក្នុងរយៈពីរបីឆ្នាំដំបូងនៃជីវិតគាត់?**
គឺទ្រង់ទុកជីវិតអោយគាត់រស់នៅ ធ្វើដូច្នេះទើបគាត់អាចនឹងទទួលនូវការបង្រៀន ពីផ្ទះរបស់ឪពុកម្តាយបង្កើតរបស់គាត់ផ្ទាល់។ (និក្ខមនំ ២:៨-១០)

**៣. តើធ្វើដូចម្តេចទើបអោយយើងដឹងថា ព្រះជាអ្នករៀបចំផែនការណ៍ អោយគាត់បានទៅរស់ក្នុងរាជ្យវាំងរបស់ស្តេច?**
គាត់បានសិក្សាស្វែងយល់ពីឧត្តមគតិ របស់សាសន៍អេស៊ីប ហើយបន្ទាប់ មកគាត់សិក្សាពីប្រជារាស្ត្រព្រះជាម្ចាស់ម្តង។ (កិច្ចការ ៧:២២)


Copyright © Gratia Dei Sola Media

**៤. តើលោកម៉ូសេបានរៀបចំយ៉ាងដូចម្ដេចទៀតនៅថ្ងៃខាងមុខ?**

គាត់ចំណាយពេលអស់ ៤០ឆ្នាំនៅស្រុកម៉ាឌាន ធ្វើជាអ្នកគង្វាលចៀម។ (និក្ខមនំ៣:១)

**៥. តើព្រះត្រាស់ហៅលោកម៉ូសេអោយទៅរំដោះប្រជារាស្ត្រ ទ្រង់យ៉ាងដូចម្ដេច?**

ទ្រង់មានព្រះបន្ទូលទៅកាន់គាត់ពីគុម្ពបន្លាដែលកំពុងឆេះឥតសស់ ហើយទ្រង់ក៏ប្រទានអោយគាត់នូវទីសំគាល់នៃការអស្ចារ្យ សំរាប់បង្ហាញដល់ស្ដេចផារ៉ោនដែរ។
(និក្ខមនំ ៣:១-១០, ៤:១-៩)

**៦. តើស្ដេចផារ៉ោនមានបំណង ដោះលែងប្រជារាស្ត្រអ៊ីស្រាអែលដែរឬទេ?**

ទេ! ព្រះបណ្ដាលអោយស្ដេចផារ៉ោនមានចិត្តរឹង ដើម្បីអោយទ្រង់បង្ហាញពីអំណាចេស្ដារបស់ទ្រង់។
(និក្ខមនំ ៧:៤, រ៉ូម ៩:១៧-១៨)

**៧. តើព្រះសំដែងឫទ្ធានុភាព និងចេស្ដាទ្រង់ក្នុងប្រទេសអេស៊ីបយ៉ាងណា?**

ព្រះជាម្ចាស់ទ្រង់បានបញ្ជូនគ្រោះកាចទាំង១០ ដើម្បីអោយស្ដេចផារ៉ោនដឹងថា ទ្រង់គឺជាព្រះពិតដែលមានព្រះជន្មគង់នៅមែន។ (និក្ខមនំ៣:១៤,៧:១៤-១២:៣០)


Copyright © Gratia Dei Sola Media

**៨. តើព្រះបង្គាប់ទៅលោកម៉ូសេ និងប្រជារាស្ត្រអ៊ីស្រាអែលអោយធ្វើដូចម្ដេច ពេលដែលព្រះបានបញ្ជូនគ្រោះកាចចុងក្រោយមកលើប្រទេសអេស៊ីប?**

តំរូវអោយរក្សាថ្ងៃបុណ្យនំប៉័ងឥតដំបែជាប់ជានិច្ច។ (និក្ខមនំ ១២:១-២៨)

**៩. តើពីធីបុណ្យនំប៉័ងឥតដំបែនេះមានន័យបែបណា?**

គឺបង្ហាញពីព្រះលោហិតរបស់ព្រះគ្រីស្ទ ដែលខ្ចាយនៅលើឈើឆ្កាង។ (១កូរិនថូស៥:៧-៨,១ពេត្រុស១:១៨-២៣)

**១០.តើមានសារៈសំខាន់បែបណា ពីការរំដោះរាស្ត្រអ៊ីស្រាអែលរហូតមកដល់សមុទ្រក្រហមនេះ?**

វាបានគូសបញ្ជាក់អោយឃើញពីការរំដោះដ៏អស្ចារ្យជាលើកទីពីរ ដែលព្រះបានប្រទានអោយពួកជំនុំរបស់ទ្រង់។

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១០៥:៤) ចូររកព្រះយេហូវ៉ា និងព្រះចេស្ដារបស់ទ្រង់ចូររកព្រះភ័ក្រទ្រង់ជានិច្ច។



Copyright © Gratia Dei Sola Media

# សម័យកាលទី ៣
# ការធ្វើដំណើររបស់ប្រជារាស្ត្រអ៊ីស្រាអែលទៅទឹកដីស្រុកកាណានរហូតមកទល់នឹងរជ្ជកាលព្រះបាទសាឡូម៉ូន

## មេរៀនទី ១១
## ការបះបោររបស់រាស្ត្រអ៊ីស្រាអែលនៅក្នុងវាលរហោស្ថាន

**១. តើអ្វីដែលធ្វើអោយមានភាពធម្មតា ក្នុងការធ្វើដំណើររបស់រាស្ត្រអ៊ីស្រាអែលក្នុងវាលរហោស្ថាន?**

គឺពួកគេបានត្រឡប់ទៅជាប្រជារាស្ត្រ ដែលមានការបះបោរប្រឆាំង។ (ជនគណនា២០:១-៥,២១:៥)

**២. តើរាស្ត្រអ៊ីស្រាអែលបង្ហាញពីការបះបោរប្រឆាំង របស់ពួកគេយ៉ាងណា?**

ដោយចោទប្រកាន់ថាលោកម៉ូសេ និងអើរ៉ុនដឹកនាំពួកគេអោយស្លាប់ដោយការស្រេកឃ្លាននៅក្នុងវាលរហោស្ថាន។ (និក្ខមនំ១៦:១-៣,១៧:៣)

**៣. ហេតុអ្វីទើបពួកគេបោះសំដីដ៏អាក្រក់បែបនេះ ទៅកាន់លោកម៉ូសេ និងអើរ៉ុនទៅវិញ។**

ដោយសារតែពួកគេបានឈ្លក់វង្វេងនឹងម្ហូបអាហារ នៅឯស្រុកអេស៊ីប ហើយថែមទាំងគ្មានការទុកចិត្ត លើការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ចំពោះតំរូវការនានារបស់ពួកគេ។ (និក្ខមនំ១៦:៣,ជនគណនា១១:១-៦)



Copyright © Gratia Dei Sola Media

**៤. ប្រជារាស្ត្រអ៊ីស្រាអែលបានធ្វើអំពើបាបអ្វីខ្លះនៅឯ មេរីបា?**

ប្រជារាស្ត្រអ៊ីស្រាអែលរអ៊ូរទាំប្រឆាំងនឹងលោកម៉ូសេ ហើយបានបោកបញ្ឆោតព្រះ ពីព្រោះនៅទីនោះគ្មានទឹកទេ។ (និក្ខមនំ ១៧:១-៧)

**៥. តើព្រះជាម្ចាស់ សំដែងព្រះហឫទ័យស្មោះស្ម័គ្ររបស់ព្រះអង្គចំពោះពួកគេយ៉ាងដូចម្តេច?**

គឺព្រះជាម្ចាស់បានប្រទាននំម៉ាណាពីស្ថានសួគ៌ និងប្រទានអោយមានទឹកផុសចេញពីថ្មសំរាប់ពួកគេ។ (និក្ខមនំ ១៦:១៤-១៥, ១៧:៦-៧)

**៦. តើជ័យជំនះបែបណា ដែលព្រះជាម្ចាស់បានប្រទានអោយរាស្ត្រអ៊ីស្រាអែលកាលនៅត្រង់រេផីឌីម?**

ប្រជារាស្ត្រអ៊ីស្រាអែលបានឈ្នះលើសាសន៍អាម៉ាលេក កាលណាលោក ម៉ូសេលើកដៃគាត់ឡើងទៅស្ថានសួគ៌។ (និក្ខមនំ ១៧:៨-១៦)

**៧. តើអំពើបាបដ៏សែនធំមួយណា ដែលរាស្ត្រអ៊ីស្រាអែលបានប្រព្រឹត្តកាលនៅត្រង់ភ្នំស៊ីណៃ?**

ពួករាស្ត្រអ៊ីស្រាអែលបាននាំគ្នាសូនរូបកូនគោមាស ដើម្បីថ្វាយបង្គំ។ (និក្ខមនំ ៣២)



Copyright © Gratia Dei Sola Media

**៨. តើការថ្វាយបង្គំកូនគោមាសនោះជាអំពើបាបបែបណា?**
នោះគឺជាអំពើបាប នៃការថ្វាយបង្គំរូបសំណាក។
(កិច្ចកា៧:៣៨-៤៣)

**៩. តើព្រះបំបាត់ប្រជារាស្ត្រអ៊ីស្រាអែលចោល ដោយសារអំពើបាប នៃការថ្វាយបង្គំរូបសំណាកនៅក្នុងថ្ងៃនោះមែនឬទេ?**
ទេ! ព្រះទុកជីវិតអោយពួកគេ ជាប្រយោជន៍ដល់ពូជដែលទ្រង់ជ្រើសតាំង។ (និក្ខមនំ៣២:៣០-៣៣:១១)

**១០.តើក្នុងប្រវត្តិសាស្ត្រទាំងនេះ ព្រះសព្វព្រះហឫទ័យបង្ហាញអោយដឹងពីអ្វីខ្លះ?**
ដើម្បីអោយយើងបានដឹងថា ពួកយើងបានសង្គ្រោះដោយសារព្រះគុណនៃព្រះ គឺមិនមែនពីការល្អដែលយើងប្រព្រឹត្តិឡើយ។

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង១០៥:៥-៦) [៥]ត្រូវអោយនឹកចាំពីការអស្ចារ្យ ដែលទ្រង់បានធ្វើហើយពីការចំឡែក និងបញ្ញត្ត ទាំងប៉ុន្មានដែលចេញពីព្រះឱស្ឋទ្រង់មក [៦]ឱពូជពង្សនៃអ័ប្រាហាំជាអ្នកបំរើទ្រង់ គឺអស់ទាំងកូនចៅរបស់យ៉ាកុបជាពូជជ្រើសតាំងរបស់ទ្រង់អើយ។


Copyright © Gratia Dei Sola Media

# មេរៀនទី ១២
# ប្រជារាស្ត្រអ៊ីស្រាអែលទទួលក្រឹត្យវិន័យ

**១. ហេតុអ្វីបានជាព្រះដឹកនាំប្រជារាស្ត្រអ៊ីស្រាអែល ទៅកាន់ភ្នំស៊ីណៃ?**

គឺដើម្បីរៀបចំជីវិតពួកគេអោយរស់នៅ ជាសាសន៍នៃសម្ព័ន្ធមេត្រីរបស់ព្រះ។ (និក្ខមនំ២១-២៣:២៦,ហេព្រើ៩)

**២. តើព្រះប្រទានអ្វីដល់ប្រជារាស្ត្រអ៊ីស្រាអែល នៅភ្នំស៊ីណៃ ដើម្បីអោយពួកគេក្លាយទៅជាជាតិសាសន៍នៃសម្ព័ន្ធមេត្រី?**

គឺបានប្រទាននូវក្រឹត្យវិន័យ១០ប្រការ និងច្បាប់រដ្ឋប្បវេណី ហើយនិងបញ្ញត្តិនៃពិធីផ្សេងៗ ។ (ចោទិយកថា១០:៤)

**៣. តើព្រះតំរូវអោយយើងធ្វើដូចម្តេចដែរ ចំពោះក្រឹត្យវិន័យទាំង១០ប្រការនោះ?**

គឺថាយើង "ចូរស្រឡាញ់ដល់ព្រះនៃឯងអោយអស់អំពីចិត្តអស់អំពីព្រលឹង អស់អំពីគំនិត និងអស់អំពីកំឡាំងនៃឯង ហើយត្រូវស្រឡាញ់អ្នកជិតខាង ដូចស្រលាញ់ខ្លួនឯងដែរ"។
(ម៉ាកុស ១២:៣០-៣១) (WSC 42)



Copyright © Gratia Dei Sola Media

**៤. តើក្រឹត្យវិន័យបានបង្រៀនដូចម្តេចខ្លះទាក់ទិន នឹងខ្លួនយើងផ្ទាល់?**

ជាធម្មតាបង្រៀនយើងថាៈ គឺយើងម្នាក់ៗឆាប់ស្អប់ខ្ពើមព្រះ និងអ្នកជិតខាងណាស់។ (រ៉ូម ៧:៧,កាឡាទី៥:១៩-២១)

**៥. តើព្រះជាម្ចាស់បានប្រើក្រឹត្យវិន័យ ដើម្បីបង្រៀនសាសន៍អ៊ីស្រាអែល ទាក់ទិននឹងការសង្គ្រោះរបស់ពួកគេដូចម្តេច?**

តាមរយៈក្រឹត្យវិន័យ ទ្រង់បង្រៀនសាសន៍អ៊ីស្រាអែលអោយរង់ចាំការយាងមករបស់ព្រះគ្រីស្ត។ (កាឡាទី ៣:២៤)

**៦. តើព្រះជាម្ចាស់បានប្រទានអ្វីផ្សេងទៀត ក្រៅពីក្រឹត្យវិន័យទាំងនេះទេ?**

ទ្រង់ប្រទានផែនការណ៍ ក្នុងការកសាងរោងឧបោសថ។ (និក្ខមនំ២៥-២៧:២១)

**៧. តើរោងឧបោសថបានចង្អុលបង្ហាញពីព្រះគ្រីស្ទដូចម្តេច?**

គឺជាសណ្ឋាននៃព្រះគ្រីស្ទ ដែលទ្រង់មានលក្ខណៈជាមនុស្សមួយរយភាគរយ និងជាព្រះមួយរយភាគរយ ហើយស៊ូមករស់នៅជាមួយនឹង មនុស្សលោក (យ៉ូហាន ១:១៤) ក្នុងពេលថ្វាយយញ្ញបូជានៅមុខរោងឧបោសថគឺជាបែបផែននៃព្រះរាជ្យកិច្ចរបស់ទ្រង់ដែលតំរូវអោយសោយទីវង្គត់ សំរាប់លោះបាបរបស់យើងរាល់គ្នា។ (យ៉ូហាន ១:១៤, ហេព្រើ ៨:១០)


Copyright © Gratia Dei Sola Media

**៨. ហេតុអ្វីបានជារោងឧបោសថនោះ ត្រូវបានហៅថាជាព្រះដំណាក់របស់ព្រះជាម្ចាស់?**

ពីព្រោះជានិមិត្តរូបដំណាងថា ព្រះកំពុងតែគង់នៅជាមួយនឹងរាស្ត្ររបស់ទ្រង់។ (និក្ខមនំ២៥:២២)

**៩. តើព្រះជាម្ចាស់រស់នៅជាមួយនឹងរាស្ត្ររបស់ទ្រង់ នៅក្នុងរោងឧបោសថបានយ៉ាងដូចម្តេច?**

នៅលើពពកដែលពេញដោយសិរីល្អនៅក្នុងទីបរិសុទ្ធបំផុត។ (និក្ខមនំ ៤០:៣៤)

**១០. តើវាជាក់ស្តែងណាស់មែនទេ កាលដែលសាសន៍អ៊ីស្រាអែលមិនសមនឹង ទទួលបាននូវព្រះវត្តមានព្រះគង់នៅជាមួយគេ?**

ពិតមែន ព្រោះសាសន៍អ៊ីស្រាអែលបានបំរើដល់រូបសំណាក់កូនគោមាស ពេលដែលលោកម៉ូសេបានចុះមកពីលើភ្នំ។ (និក្ខមនំ ៣២)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១០៥:៧-៨) [៧]ទ្រង់ជាព្រះនៃយើងខ្ញុំ ព្រះនាមព្រះយេហូវ៉ា ឯបញ្ញត្តទាំងប៉ុន្មានរបស់ទ្រង់ក៏នៅពេញពាសលើផែនដី [៨]ទ្រង់បាននឹកចាំពីសេចក្តីសញ្ញាទ្រង់ជានិច្ច គឺជាព្រះបន្ទូលដែលទ្រង់បានបង្គាប់ ដល់មនុស្សទាំងពាន់ដំណ។



Copyright © Gratia Dei Sola Media

# មេរៀនទី ១៣
# ពួកជំនុំនៅក្នុងវាលរហោស្ថាន

**១. តើមានការបង្ហាញដូចម្ដេច ពីការនិយាយពីការធ្វើដំណើររបស់ពួកអ៊ីស្រាអែលទៅកាន់ស្រុកកាណាន?**
អ៊ីស្រាអែលមិនត្រូវបានអនុញ្ញាត្តិអោយទៅស្រុកកាណានជាច្រើនឆ្នាំ ព្រោះពួកគេគ្មានជំនឿ។ (ជនគណនា១៣,១៤)

**២. តើពួកគេបានបង្ហាញពីភាពគ្មានជំនឿរបស់ពួកគេដូចម្ដេច?**
ពួកគេបដិសេដ្ឋ ចំពោះការរាយការណ៍របស់យ៉ូស្វេ និង កាឡែប ហើយបានជឿលើការរាយការណ៍កុហក់ដោយអ្នកស៊ើបការ១០នាក់ផ្សេងទៀតវិញ។ (ជនគណនា ១៤:១៤,១០)

**៣. ហេតុអ្វីបានជាទង្វើរបែបនេះបង្ហាញពីការដែលគ្មានជំនឿទៅវិញ?**
ពីព្រោះពួកគេមិនទុកចិត្តការសំរេចនៃព្រះបន្ទូលសន្យាសម្ព័ន្ធមេត្រីដែល ថាទ្រង់នឹងប្រទានទឹកដីនោះអោយពួកគេ។ (ជនគណនា១៣:៣០-៣៣ ,១៤ :៥-៩)

**៤. តើព្រះដាក់ទោសចំពោះការមិនជឿបែបនេះយ៉ាងដូចម្ដេច?**
គឺទ្រង់ដាក់បណ្ដាសាសាសន៍អ៊ីស្រាអែល ដោយអោយពួកគេដើរគ្មានកោះត្រើយ ក្នុងវាលរហោស្ថានរយៈពេល៤០ឆ្នាំ។ (ទំនុកដំកើង៩៥:១០,ជនគណនា ១៤:៣៣)


Copyright © Gratia Dei Sola Media

**៥. តើក្នុងអំឡុងពេល៤០ឆ្នាំ ក្នុងវាលរហោស្ថានមានរឿងអ្វីខ្លះកើតឡើង?**

រយៈពេល២០ឆ្នាំបានកន្លងផុតទៅ គឺនៅសល់តែយ៉ូស្វេ និង កាឡែបប៉ុណ្ណោះ ដែលបានរួចផុតជីវិតពីការស្លាប់នៅក្នុងទីរហោស្ថាន។ (ជនគណនា ១៤:១៩-៣៩)

**៦. តើការតែលតោលក្នុងពេលនោះ មានលក្ខណៈដូចម្ដេច?**

វាគឺជាពេលមួយដែលពោរពេញទៅដោយការរអ៊ូរទាំ បះបោរប្រឆាំងដ៏សែនអាក្រក់ជាទីបំផុត។(ទំនុកដំកើង ៩៥:១០)

**៧. តើអ្វីទៅដែលជាការសំគាល់ពីគំរូទាំងពីរ នៃការបះបោររបស់ពួកអ៊ីស្រាអែលប្រឆាំងនឹងព្រះជាម្ចាស់?**

ការបះបោររបស់ កូរេ ដាថាន និងអ័ប៊ីរ៉ាម ប្រឆាំងនឹងលោកម៉ូសេ និងអើរ៉ុន(ជនគណនា ១៦) មួយទៀត គឺប្រជាជនបានស្អប់ខ្ពើមនឹងនំម៉ាណារបស់ព្រះ ហើយពួកគេបានចោទប្រកាន់ទ្រង់ថា ជាអ្នកនាំពួកគេអោយស្លាប់នៅវាលរហោស្ថាននេះ។ (ជនគណនា ១៦, ២១:៤-៩ )

**៨. តើព្រះដាក់ទោសពួកអ៊ីស្រាអែលចំពោះអំពើបាប ដែលគេស្អប់ខ្ពើមនំម៉ាណារបស់ទ្រង់យ៉ាងដូចម្ដេច?**

ព្រះចាត់ពស់ភ្លើងអោយមកសំឡាប់ពួកគេអស់ជាច្រើននាក់។ (ជនគណនា ២១:៨-៩)



Copyright © Gratia Dei Sola Media

**៩. តើព្រះបាបសង្គ្រោះពួកគេពីការសំឡាប់របស់ពស់ភ្លើងយ៉ាងដូចម្ដេច?**

ទ្រង់មានព្រះបន្ទូលប្រាប់អោយលោកម៉ូសេធ្វើពស់ភ្លើង ធ្វើពីសង្ហិនមួយដាក់ភ្ជាប់នៅលើបង្គោល ហើយអស់អ្នកណាដែលបានក្រឡេកមើលពស់រូបពស់ភ្លើងសង្ហិននោះនឹងបានសង្គ្រោះ។ (ជនគណនា ២១:៨-៩)

**១០.តើពស់លង្ហិននោះគឺជាការសំគាល់ទៅលើអ្វី?**

ដូចដែលព្រះយេស៊ូវគ្រីស្ទមានព្រះបន្ទូលថា "ហើយដែលលោកម៉ូសេ បានលីសត្វពស់ឡើងនៅទីរហោស្ថានយ៉ាងណា នោះកូនមនុស្សនឹងត្រូវ លើកឡើងយ៉ាងនោះដែរ ដើម្បីអោយអស់អ្នកណាដែលជឿដល់កូនមនុស្សនោះមិនត្រូវវិនាសឡើយ គឺអោយមានជីវិតអស់កល្បជានិច្ចវិញ"។ (យ៉ូហាន ៣:១៤-១៥)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១០៥:៩-១០) [៩]ជាសេចក្ដីសញ្ញាដែលទ្រង់បានតាំង នឹងអ័ប្រាហាំ និងសម្បថដែលបានស្បថនឹងអ៊ីសាកផង [១០]ក៏បានតាំងសេចក្ដីនោះដល់យ៉ាកុបទុកជាច្បាប់ដល់អ៊ីស្រាអែលសំរាប់ជាសេចក្ដីសញ្ញា ដ៏នៅអស់កល្បជានិច្ច។



Copyright © Gratia Dei Sola Media

# មេរៀនទី ១៤
# សាសន៍អ៊ីស្រាអែលចូលទៅក្នុងទឹកដីសន្យា

១. **ហេតុអ្វីបានជាព្រះហាមមិនអោយលោកម៉ូសេ ដឹកនាំសាសន៍អ៊ីស្រាអែលចូលទៅក្នុងទឹកដីស្រុកកាណាន?**
ព្រោះគាត់មានកំហឹងច្រឡោតនឹងសាសន៍អ៊ីស្រាអែល ហើយគាត់បានវាយថ្មយ៉ាងខ្លាំង។ (ជនគណនា ២០:១-១៣)

២. **តើទង្វើរបស់លោកម៉ូសេបានប្រព្រឹត្តនោះបានបង្ហាញអោយឃើញអំពីអ្វី?**
គាត់គ្រាន់តែមានលក្ខណៈសម្បត្តិ អាចធ្វើជាអ្នកសំរុះសំរួលប៉ុណ្ណោះ។
(ជនគណនា២០:១២;២៧:១៤;ទំនុកដំកើង១០៦:៣២-៣៣)

៣. **តើនរណាដែលមានលក្ខណៈសម្បត្តិ ធ្វើជាអ្នកសំរុះសំរួលដូចលោកម៉ូសេ?**
ព្រះគ្រីស្ត គឺជាអ្នកសំរុះសំរួលនៃសម្ព័ន្ធមេត្រីដ៏ប្រសើរឧត្តមបំផុត។ (ហេព្រើរ៨:៦)

៤. **តើព្រះបានត្រាស់ហៅនរណា ដើម្បីអោយដឹកនាំរាស្ត្រអ៊ីស្រាអែលបន្តចូលក្នុងទឹកដីកាណាន?**
គឺលោកយ៉ូស្វេ ព្រោះគាត់ក៏មានលក្ខណៈសម្បត្តិដូចព្រះគ្រីស្តផងដែរ។ (យ៉ូស្វេ ១:១-២)



Copyright © Gratia Dei Sola Media

**៥. តើព្រះបង្ហាញអោយដឹងថា ទ្រង់បានបើកផ្លូវទៅស្រុកកាណាន យ៉ាងដូចម្ដេច?**

ព្រោះទ្រង់ញែកទឹកទន្លេយ័រដាន់នៅចំពោះមុខពួកគេ។ (យ៉ូស្វេ ៣)

**៦. តើចាប់ពីណាដល់ណា ផ្នែកខាងលិចទន្លេយ័រដាន់ដែលសាសន៍អ៊ីស្រាអែលវាយដណ្ដើមបានមុនគេ?**

គឺចំណុចកណ្ដាលដោយចាប់តាំងពីទីក្រុងយេរីខូមក។ (យ៉ូស្វេ ៦)

**៧. តើព្រះអង្គចង់បង្ហាញពីអ្វីដែលទ្រង់បានសង្គ្រោះនាងរ៉ាហាប និងគ្រួសាររបស់នាង?**

គឺព្រះអង្គចង់បង្រួបបង្រួមរាស្ត្ររបស់ទ្រង់ ចេញពីសាសន៍ដទៃផងដែរ។ (ទំនុកដំកើង ៨៧:១-៥)

**៨. តើការសង្គ្រោះរបស់នាងរ៉ាហាបក៏ជាព្រះបន្ទូលសន្យាដែលព្រះបានសន្យានឹងលោកអ័ប្រាហាំដែរមែនទេ?**

មែនហើយ ដោយទ្រង់មានបន្ទូលប្រាប់គាត់ថា "គ្រប់ទាំងសាសន៍នៅ លើផែនដីនឹងបានពរដោយសារពូជឯង"។ (លោកុប្បត្តិ ២២:១៨)



Copyright © Gratia Dei Sola Media

**៩. តើសាសន៍អ៊ីស្រាអែលវាយដណ្តើមបានទឹកដីតំបន់ផ្សេងទៀត នៅផ្នែកខាងលិចទន្លេយ័រដាន់ត្រង់កន្លែងណាទៀត?**

គឺស្រុកភ្នំតំបន់ផ្នែកខាងត្បូង ហើយបន្ទាប់មកស្រុកតំបន់ភ្នំផ្នែងខាងជើង។ (យ៉ូស្វេ ១១:១៦-១៧)

**១០.ហេតុអ្វីបានទឹកដីនោះត្រូវបានបែងចែកក្នុងចំណោម១២ កុលសម្ព័ន្ធ?**

ទ្រង់បានចែកទឹកដីទាំងនោះដល់កុលសម្ព័ន្ធទាំង១២ ទុកជាចំណែក។ (យ៉ូស្វេ១៣:១-៨;១៩:១-៥)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១០៥:១១-១៣) [១១]ដោយបន្ទូលថា អញនឹងអោយស្រុកកាណានដល់ឯងទុកជាចំណែកមរតករបស់ឯង [១២]គ្រានោះគេមានគ្នាចំនួនតិច អើមានតិចណាស់ហើយក៏គ្រាន់តែស្នាក់នៅក្នុងស្រុកនោះផង [១៣]គេជាអ្នកដើរចុះឡើងពីនគរមួយទៅនគរមួយ ហើយពីស្រុកមួយទៅសាសន៍មួយទៀត



Copyright © Gratia Dei Sola Media

# មេរៀនទី ១៥

## អំពើបាបនានារបស់សាសន៍អ៊ីស្រាអែលនៅក្នុងទឹកដីសន្យា

**១. តើសាសន៍អ៊ីស្រាអែលនៅតែស្មោះត្រង់នឹងព្រះជាម្ចាស់ទៀតដែរឬទេ ពេលដែលរស់នៅក្នុងទឹកដីសន្យានោះ?**
ទេ! គឺពួកគេបានបោះបង់ចោលព្រះជាម្ចាស់យ៉ាងឆាប់រហ័ស ហើយបែរជាទៅគោរពរូបសំណាកជំនួសព្រះជាម្ចាស់វិញ។ (ចៅហ្វាយ២:១១-១៣)

**២. តើហេតុអ្វីដែលបណ្តាលអោយកើតមានការមិនស្តាប់បង្គាប់យ៉ាងដូច្នេះ?**
គឺឪពុកម្តាយទាំងអស់មិនអប់រំកូនចៅរបស់គេអោយចេះគោរពកោតខ្លាចព្រះទេ។ (ចៅហ្វាយ ២:១០)

**៣. តើសាសន៍អ៊ីស្រាអែលបានបំផ្លាញអស់អ្នកដែលមិនជឿលើព្រះក្នុងទឹកដីកាណាន ដូចដែលព្រះបានបង្គាប់ដែរឬទេ?**
ទេ! គឺពួកគេមិនស្តាប់បង្គាប់ព្រះជាម្ចាស់ឡើយ ហើយថែមទាំងចងសម្ព័ន្ធមិត្តជាមួយជាតិសាសន៍ជាច្រើនទៀតផង។ (ចៅហ្វាយ ២:១-២)


Copyright © Gratia Dei Sola Media

## ៤. តើព្រះបានដាក់ទោសសាសន៍អ៊ីស្រាអែលយ៉ាងដូចម្តេចក្នុងការដែលពួកគេចងសម្ព័ន្ធមិត្តជាមួយជាតិសាសន៍ដែលជាសត្រូវរបស់ទ្រង់ដូច្នេះ?

ព្រះទ្រង់បានចំរើនកំឡាំងដល់ជាតិសាសន៍ទាំងនោះ ហើយប្រគល់សាសន៍អ៊ីស្រាអែលទៅក្នុងកណ្តាប់ដៃរបស់គេ។ (ចៅហ្វាយ ២ និង ៣)

## ៥. តើព្រះនឹងចាំអំពីរាស្ត្រទ្រង់ឬទេពេលដែលពួកគេជួបនឹងទុក្ខវេទនា?

មែនហើយ គឺព្រះអង្គបានចាត់បញ្ជូនពួកចៅហ្វាយអោយទៅរំដោះពួកគេ ពេលដែលពួកគេបានលន់តួអំពើបាបរបស់ខ្លួន។ (ចៅហ្វាយ២:១៦-១៨)

## ៦. តើព្រះជាម្ចាស់បានបង្រៀនមេរៀនអ្វីតាមរយៈកងទ័ពមួយក្រុមតូចរបស់លោកគីឌាន?

ទ្រង់បានបង្រៀនថា ជ័យជំនះគឺសុទ្ធតែមកពីព្រះជាម្ចាស់។ (ចៅហ្វាយ៧:១-៧)

## ៧. តើពេលដែលព្រះបន្ទូលបានមកដល់ទឹកដីអ៊ីស្រាអែលទ្រង់បាននិយាយទៅមួយអ្នកណា?

ទ្រង់បាននិយាយជាមួយលោកសាំយូអែលដែលជាហោរាហើយក៏ជាសង្ឃនៃព្រះ។ (១សាំយ៉ូអែល៣:១៩-៤:១)



Copyright © Gratia Dei Sola Media

**៨. តើសាសន៍អ៊ីស្រាអែលស្នើរឿងដ៏អាក្រក់អ្វីទៅកាន់លោកសាំយូអែល?**

ពួកគេសុំហោរាសាំយូអែល តាំងអោយមានស្ដេចមួយដូចសាសន៍ដទៃដែរ។ (១សាំយ៉ូអែល៨)

**៩. ហេតុអ្វីបានជារឿងអាក្រក់ដែលសាសន៍អ៊ីស្រាអែល ចង់តាំងអោយមានស្ដេចមួយអង្គឡើងគ្រងរាជ្យ?**

ពីព្រោះថាក្នុងការដែលពួកគេទាមទារដូច្នេះ គឺបញ្ជាក់ថាពួកគេកំពុង តែបដិសេធព្រះអម្ចាស់ដែលជាស្ដេចរបស់គេ។ (១ សាំយូអែល ៨:៧)

**១០.តើក្នុងសម័យកាលនៃពួកចៅហ្វាយមានលក្ខណៈដូចម្ដេច?**

គឺមនុស្សទាំងឡាយបានប្រព្រឹត្តការអ្វីៗ ដែលគេយល់ឃើញថាសុទ្ធតែត្រឹមត្រូវក្នុងកែវភ្នែករបស់គេផ្ទាល់។ (ចៅហ្វាយ ២១:២៥)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១០៥:១៤-១៥) [១៤]តែទ្រង់មិនបើកអោយអ្នកណាសង្កត់សង្កិនគេឡើយ អើ ទ្រង់បានផ្ចាល់ទាំងពួកស្ដេចដោយយល់ដល់គេ [១៥]ដោយថាកុំអោយប៉ះពាល់នឹងអ្នកដែលអញបានចាក់ប្រេងតាំងអោយ ហើយកុំអោយប្រទូសរ៉ាយដល់ពួកហោរារបស់អញឡើយ។


Copyright © Gratia Dei Sola Media

# មេរៀនទី ១៦

# សាសន៍អ៊ីស្រាអែលទទួលបានទឹកដីសន្យាទាំងអស់ ទុកជាកេរមរតក

**១.តើព្រះប្រទានស្តេចមួយអង្គដូចដែលពួកគេបានទូលសូមទេ?**

មែនហើយ គឺទ្រង់បានប្រទានសូលអោយឡើងសោយរាជ្យធ្វើជាស្តេច។ (១សាំយ៉ូអែល១០)

**២. តើព្រះជាម្ចាស់បានចាក់ប្រេងតាំងអោយនរណាឡើងសោយរាជ្យជំនួសសូល នៅពេលដែលគាត់បានបដិសេធព្រះអង្គ?**

គឺព្រះអង្គបានចាក់ប្រេងតាំងដល់ដាវីឌ អោយឡើងសោយរាជ្យជាស្តេចដ៏ជាធិបតេយ្យបន្តពីសូល។ (១សាំយូអែល ១៦)

**៣. តើព្រះបានប្រទានអ្វីខ្លះដល់សាសន៍អ៊ីស្រាអែលតាមរយៈស្តេចដាវីឌ ?**

តាមរយៈស្តេចដាវីឌ ព្រះជាម្ចាស់បានប្រទាននូវទឹកដីសន្យាទាំងប៉ុន្មានដល់សាសន៍អ៊ីស្រាអែល ដែលទ្រង់បានសន្យាជាមួយនឹងលោកអ័ប្រាហាំ។ (លោកុប្បត្តិ១៥:១៨-២១)



Copyright © Gratia Dei Sola Media

**៤. ហេតុអ្វីបានជាស្តេចដាវីឌមិនអាចសាងសង់ព្រះវិហារបាន?**
ព្រោះគាត់បានកំចាយឈាមជាច្រើន ហើយធ្វើចំបាំងធំៗជាច្រើន។ (របាក្សត្រ២២:៨)

**៥. តើព្រះសន្យាជាមួយស្តេចដាវីឌយ៉ាងណាជាមួយការសាងសង់ព្រះវិហារ?**
គឺទ្រង់នឹងប្រទានកូនប្រុសម្នាក់ដល់ស្តេចដាវីឌ ដែលអាចសង់វិហារនោះបាន។ (២សាំយូអែល ៧:១២-១៣)

**៦. តើមានសារៈសំខាន់អ្វី ដែលព្រះវិហារព្រះបាទសាឡូម៉ូនមានក្នុងជីវិតសាសន៍អ៊ីស្រាអែល?**
វាគឺជាចំណុចកណ្តាលនៃរដ្ឋាភិបាល។
(ចោទិយកថា១២:១៣; ១របាក្សត្រ ២២:៦-១៩)

**៧. តើព្រះវិហារនេះអាចជាចំណុចកណ្តាលនៃអធិបតេយ្យភាពក្នុងចំណោមសាសន៍អ៊ីស្រាអែលបានយ៉ាងដូចម្តេច?**
ពីព្រោះព្រះរើសវាដើម្បីតាំងជាសញ្ញាពីព្រះវត្តមាន របស់ទ្រង់គង់នៅក្នុងចំណោមរាស្ត្រនៃសម្ព័ន្ធមេត្រីរបស់ព្រះអង្គ។
(១របាក្សត្រ២២:១៩, និក្ខមនំ២៥:២២)

**៨. តើរជ្ជកាលព្រះបាទសាឡូម៉ូនមានលក្ខណៈយ៉ាងដូចម្តេច?**
វាជារជ្ជកាលមួយដែលមានសុខសន្តិភាព និងភាពថ្កុំថ្កើងដ៏រុងរឿង។ (១ពង្សាវតាក្សត្រ៤:២១-២៥,១របាក្សត្រ២២:៩)


Copyright © Gratia Dei Sola Media

**៩. តើជ័យជំនះទាំងឡាយរបស់ស្តេចដាវីឌលើខ្មាំងសត្រូវគឺជាសណ្ឋានមួយដែលបង្ហាញអំពីអ្វី?**

គឺបង្ហាញពីជ័យជំនះរបស់ព្រះយេស៊ូវ លើអំពើបាបរបស់រាស្ត្រទ្រង់ ជ័យជំនះលើវិញ្ញាណអាក្រក់ និងលោកិយដ៏ស្មោគគ្រោកនេះ។ (លូកា ១:៧៤-៧៥,ទំនុកដំកើង៥៦,៧២:១-៩)

**១០. តើភាពសុខសាន្ត និងភាពថ្កុំថ្កើងរុងរឿងក្នុងរជ្ជកាលព្រះបាទសាឡូម៉ូន ជាសណ្ឋានមួយដែលបង្ហាញអំពីអ្វី?**

គឺបង្ហាញពីសិរីល្អ និងសោភ័ណភាពនៃព្រះរាជ្យរបស់ព្រះគ្រីស្តដែល នឹងត្រូវយាងមក។ (១ពង្សាវតាក្សត្រ៤:២១-២៥, អេសាយ៩:៦-៧, ១១:៦-៩, វិវរណៈ១២:១០-១១, អេភេសូរ ២:១៤-១៧)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៤៥:១-២) [១]ចិត្តរបស់ខ្ញុំពេញហៀរដោយសេចក្តីដ៏ល្អ គឺខ្ញុំនិយាយអំពីសេចក្តីដែលខ្ញុំបាននិពន្ធពីដំណើរមហាក្សត្រ អណ្តាតខ្ញុំជាស្លាបប្រការនៃអ្នកតែងរឿងយ៉ាងជំនាញ [២]ទ្រង់ព្រះករុណាល្អវិសេសជាងអស់ទាំងពួកមនុស្សព្រះរឹមទ្រង់ប្រកបដោយព្រះគុណ ហេតុនោះបានជាព្រះបានប្រទានពរដល់ទ្រង់ជាដរាបតទៅ។



Copyright © Gratia Dei Sola Media

# សម័យកាលទី ៤
# ការបែងចែករាជ្យ ដើម្បីងាកចេញពីភាពជាទាសករ

## មេរៀនទី ១៧
## ការបែងចែករាជ្យ

**១. តើអាណាចក្រព្រះបាទសាឡូម៉ូន សំរេចតាមព្រះបន្ទូលសន្យា ដែលព្រះសន្យាជាមួយលោកអ័ប្រាហាំឬ?**
វាគឺជាបែបផែននៃការសំរេចព្រះបន្ទូលសន្យានោះ។
(លោកុប្បត្តិ១៧: ៦-៨)

**២. តើអ្វីដែលជាការពិត ទាក់ទិនទៅនឹងបែបផែនដ៏មុតស្រួចនេះ?**
គឺអាណាចក្រដ៏នៅអស់កល្បរបស់ព្រះ នៅស្ថានសួគ៌នៃទឹកដីកាណាន។ (ហេព្រើ ១១:៨:១០, ១៣-១៦, វិវរណៈ ៥:៦-១៤)

**៣. តើព្រះដាក់ទោសព្រះបាទសាឡូម៉ូន ចំពោះការថ្វាយបង្គំរូបសំណាកយ៉ាងដូចម្ដេច?**
ព្រះអង្គដកយកកុលសម្ព័ន្ធទាំង១០ ចេញពីដំណាក់របស់ស្ដេចដាវីឌ ហើយប្រគល់ពួកគេអោយទៅយេរ៉ូបោម។
(១ពង្សាវតារក្សត្រ ១១:៣៥)



Copyright © Gratia Dei Sola Media

**៤. តើការបែងចែកអាណាចក្រនេះវាជាឱកាសបែបណា?**
រេហូបោមបដិសេធការបន្ធូបន្ថយពន្ធពីប្រជាជន បន្ទាប់ពីវិមានរបស់ស្តេច និងព្រះវិហារដែលបានសង់ឡើង។ (១ពង្សាវតាក្សត្រ១២:៣-៥,១២-១៤)

**៥. ហេតុអ្វីទើបអំពើបាបក្នុងការដែលកុលសម្ព័ន្ធទាំង១០ចេញពីដំណាក់នៃស្តេចដាវីឌ?**
ដោយសារពួកគេបដិសេធព្រះគ្រីស្ត ដែលព្រះជាម្ចាស់បានតែងតាំងទ្រង់អោយគង់លើបល្ល័ង្ករបស់ស្តេចដាវីឌ។ (១ពង្សាវតាក្សត្រ១២:១៦,១៩, ២៥-២៩អេសាយ៩:៦-៧)

**៦. តើអាណាចក្រយូដាបានទទួលព្រះពរសម្ព័ន្ធអមេត្រីអ្វីទៀតក្រៅពីរាជ្យបល្ល័ង្ករបស់ស្តេចដាវីឌ?**
គឺអាណាចក្រយូដា មានព្រះដំណាក់ព្រះជាម្ចាស់ក្នុងក្រុងយេរូសាឡិម។ (១ពង្សាវតាក្សត្រ១២:២៦-២៧)

**៧. តើកុលសម្ព័ន្ធពីរណាដែលព្រះបានទុកអោយ រេហូបោមគ្រប់គ្រង?**
គឺកុលសម្ព័ន្ធ យូដា និងបេនយ៉ាមីន។ (២របាក្សត្រ ១១:១-២)



Copyright © Gratia Dei Sola Media

**៨. តើរេហូបោមបានបង្ខិតបង្ខំអោយកុលសម្ព័ន្ធទាំង១០ ទៀតទទួលស្គាល់គាត់ថាជាស្តេចរបស់ពួកគេឬទេ?**

មែនហើយ តែព្រះជាម្ចាស់មិនព្រមអោយគាត់ធ្វើចំបាំងជាមួយនឹងបងប្អូនរបស់គាត់ឡើយ។
(១ពង្សាវតារក្សត្រ ១២:២៣-២៤)

**៩. តើអ្នកអាចនិយាយអំពីស្តេចទាំងអស់របស់យូដាដូចម្តេច?**

ស្តេចទាំងអស់ សុទ្ធតែមកពីដំណាក់ស្តេចដាវីឌទាំងអស់។
(១ពង្សាវតារក្សត្រ ១១:៤៣; ១៤:៣១; ១៥:៨; ២២:៤១
២ពង្សាវតារក្សត្រ ៨:១៦)

**១០.ហេតុអ្វីបានជាស្តេចទាំងអស់នោះសុទ្ធសឹងតែមកពីដំណាក់ស្តេចដាវីឌ?**

ពីព្រោះព្រះជាម្ចាស់បានសន្យាថា នឹងកសាងបល្ល័ង្ករបស់ស្តេចដាវីឌអោយ នៅស្ថិតស្ថេរដ៏អស់កល្បជានិច្ច។
(២សាំយ៉ូអែល៧:១៦-១៧,អេសាយ៩: ៦-៧)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៤៥:៣-៤) [៣]ឱព្រះករុណាដ៏មានឥទ្ធិឫទ្ធិអើយ សូមក្រវាត់ដាវជាប់នៅត្រគាកទ្រង់ ទុកជាគ្រឿងលំអនឹងកិត្តិយសនៃទ្រង់ផង [៤]រួចជិះទៅដោយឥទ្ធិឫទ្ធិរបស់ទ្រង់មានទាំងជ័យជំនះផង ដើម្បីការពារនូវសេចក្តីពិត សេចក្តីសុភាព និងសេចក្តីសុចរិ នោះព្រះហស្តស្តាំនៃទ្រង់នឹងបង្រៀនទ្រង់ពីការដែលគួរកោតខ្លាច។



Copyright © Gratia Dei Sola Media

# មេរៀនទី ១៨

# អាណាចក្រនៃសាសន៍អ៊ីស្រាអែលត្រឡប់ទៅថ្វាយបង្គំរូបសំណាកវិញ

**១. តើបទគម្ពីរបញ្ជាក់អំពីយេរ៉ូបោម ជាស្តេចនៃកុលម្ព័ន្ធទាំង១០យ៉ាងណា?**

ព្រះអង្គហៅគាត់ថា "យេរ៉ូបោម.......ជាអ្នកដែលបាននាំអោយពួកអ៊ីស្រាអែលធ្វើបាបតាមនោះដែរ"។(២ពង្សាវតារក្សត្រ១៣:២)

**២. ហេតុអ្វីទើបព្រះហៅយេរ៉ូបោមថា ជាអ្នកនាំពួកអ៊ីស្រាអែលធ្វើអំពើបាបនៅនគរខាងជើង?**

ដោយសារគាត់បញ្ជាអោយសាសន៍អ៊ីស្រាអែលថ្វាយបង្គំរូបគោមាសថា ជាព្រះ។

(១ពង្សាវតារក្សត្រ ១២:២៨-២៩, ២ពង្សាវតារក្សត្រ ១៧:២១)

**៣. តើអំពើបាបបែបណា ដែលជាប់ជាមួយសាសន៍អ៊ីស្រាអែលនាថ្ងៃខាងមុខ?**

សាសន៍អ៊ីស្រាអែលបានវិលត្រឡប់ទៅថ្វាយបង្គំ រូបសំណាកនានាដែលជាព្រះនៃជាតិសាសន៍ ដែលមិនជឿលើព្រះពិតនៅជុំវិញទឹកដីស្រុកកាណាន។ (២ពង្សាវតារក្សត្រ ១៧:៧-១២)



Copyright © Gratia Dei Sola Media

**៤. តើសាសន៍អ៊ីស្រាអែលបានថ្វាយបង្គំរូបសំណាកពិសេសមួយណា?**

នាសម័យកាលស្ដេចអ័ហាប់ដ៏អាក្រក់ អ៊ីស្រាអែលបានថ្វាយបង្គំរូបព្រះបាល។ (១ពង្សាវតារក្សត្រ ១៦:៣០-៣៣)

**៥. តើមាននៅសល់នរណាម្នាក់ដែលស្មោះត្រង់នឹងព្រះជាម្ចាស់ដែរឬទេ?**

មែនហើយ គឺមាននៅសល់មនុស្ស៧ពាន់នាក់ដែលមិនព្រមថ្វាយបង្គំ រូបព្រះបាល។ (១ ពង្សាវតារក្សត្រ ១៩:១៨)

**៦. តើព្រះជាម្ចាស់បញ្ជូលនរណា អោយមកប្រឆាំងនឹងព្រះក្លែងក្លាយនេះ?**

គឺហោរាអេលីយ៉ា និងអេលីសេ ជាអ្នកប្រកាសថាព្រះយេហូវ៉ាជាព្រះ។ (២ពង្សាវតាក្សត្រ២:១៣-១៩;រ៉ូម១១:២-៤)

**៧. តើហោរាមួយណាដែលប្រមានប្រាប់ដល់សាសន៍អ៊ីស្រាអែលអំពីការកាត់ទោសរបស់ព្រះនឹងត្រូវមកដល់?**

ហោរាអេម៉ុស និង ហោរាហូសេ។

(ហូសេ១:១-២,៩;អេម៉ុស១:១-២;៣:១-២)



Copyright © Gratia Dei Sola Media

**៨. តើអ្នកដែលនៅសេសសល់ក្នុងកុលសម្ព័ន្ធទាំងដប់ ជ្រើសរើសយកពេលដ៏ពិសេសណា ដើម្បីមកបញ្ជាក់អំពីសេចក្តីជំនឿរបស់ពួកគេ?**

ក្នុងសម័យហេសេគាធ្វើជាស្តេចនៃពួកយូដា គឺពួកគេវិលត្រឡប់ទៅក្រុងយេរូសាឡិម អោយទាន់ថ្ងៃបុណ្យរំលង។ (២របាក្សត្រ ៣០:១០-១១)

**៩. តើព្រះដាក់ទោសកុលសម្ព័ន្ធផ្នែងខាងជើងចំពោះអំពើអាក្រក់របស់ពួក គេយ៉ាងដូចម្តេច?**

ព្រះជាម្ចាស់បានបញ្ជូនស្តេចអាសស៊ើរ ទៅនាំយកពួកគេអោយជាប់ជាទាសករ ហើយពង្រាយពួកគេ។ (២ពង្សាវតាក្សត្រ១៧)

**១០.តើនរណាដែលស្តេចអាសស៊ើរអោយអាស្រ័យនៅលើទឹកដីរបស់ពួកគេ?**

គឺជាសាសន៍សាម៉ារី ដែលជាពួកបរទេសបានមកយកផ្នែកផ្សេងៗក្នុងអាណាចក្រអាសស៊ើរ។ (២ របាក្សត្រ ១៧:២៤)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៤៥:៥-៦) [៥]ព្រួញទ្រង់មុតឆៀបដល់បេះដូងរបស់ពួកខ្មាំងសត្រូវនៃព្រះករុណា សាសន៍ទាំងប៉ុន្មាននឹងដួលចុះនៅក្រោមទ្រង់ [៦]ឱព្រះអង្គអើយ បល្ល័ង្កទ្រង់ស្ថិតស្ថេរនៅអស់កល្បជានិច្ចរៀងរាបតទៅ ឯព្រះដំបងពេជ្ររបស់រាជ្យទ្រង់នោះជាដំបងសុចរិត។



Copyright © Gratia Dei Sola Media

# មេរៀនទី ១៩

# អាណាចក្រនៃសាសន៍យូដាបានចេញមកពីព្រះជាម្ចាស់

១. **តើអាណាចក្រយូដាតូចជាងអាណាចក្រអ៊ីស្រាអែលមែនទេ?**
មែន មនុស្សដែលស្មោះត្រង់របស់ព្រះជាម្ចាស់តែងតែមាន ចំនួនតិចជាង មនុស្សដែលមិនស្គាល់ព្រះ។
(១ពង្សាវតាក្សត្រ១២:២១-២៤,២ពង្សាវតា ក្សត្រ១៩:១-៤)

២. **តើនៅក្នុងចំណោមសាសន៍យូដានៅមានមនុស្សថ្វាយបង្គំ រូបសំណាកថាជាព្រះដែរទេ?**
មែនហើយ អំពើអាក្រក់បានចំរើនឡើងយ៉ាងឆាប់រហ័សបូក រួមទាំងមនុស្សក្នុងអាណាចក្រយូដាផងដែរ។
(១ពង្សាវតារក្សត្រ ១៤:២២-២៤)

៣. **តើស្តេចទាំងឡាយទៀតនៃសាសន៍យូដាគោរពកោតខ្លាច ដល់ព្រះឬ?**
មិនមែនដូច្នេះទេ តែមានស្តេចភាគច្រើនជាអ្នកដឹកនាំសាសន៍ យូដាអោយថ្វាយបង្គំរូបសំណាកយ៉ាងខ្លាំងទៀតផង។
(២ពង្សាវតាក្សត្រ៨:១៨-១៩,២៧,១១:១-៣,១៦:២-៤)



Copyright © Gratia Dei Sola Media

**៤. តើអំពើអាក្រក់បែបណាដែលព្រះនាងអ័ថាលាព្យាយាម ប្រព្រឹត្ត?**

ព្រះនាងព្យាយាមធ្វើឃាតញាតិវង្សានុវង្សទាំងអស់របស់ស្តេចដាវីឌ។ (២របាក្សត្រ២២:១-១២)

**៥. ហេតុអ្វីវិញ្ញាណអាក្រក់ប៉ុនប៉ងធ្វើឃាតញាតិវង្សានុវង្សស្តេចដាវីឌទាំងតាមរយៈព្រះនាងអ័ថាលា?**

ពីព្រោះព្រះគ្រីស្ទនឹងត្រូវមកយកកំណើត ក្នុងពូជហ្លួងក្សត្រអង្គនេះ។ (១ពង្សាវតាក្សត្រ៩:៥,២របាក្សត្រ១៣:៥;អេសាយ៩:៦-៧)

**៦. តើព្រះទុកអោយពូជហ្លួងក្សត្រអង្គនេះនៅរស់រានមានជីវិតយ៉ាងដូចម្តេច?**

គឺទ្រង់បានរក្សាទុកកុមារ យ៉ូអាសអោយមានជីវិត រួចផុតពីការតាមសម្លាប់របស់ព្រះនាងអ័ថាលា។
(២ពង្សាវតារក្សត្រ ១១:១-២)

**៧. តើស្តេចណាខ្លះដែលសំគាល់ពីជំនឿនិងភាពបរិសុទ្ធក្លៀវក្លារបស់ពួកគេ?**

អាសា យ៉ូអាស ហេសេគា យ៉ូសេ គឺជាស្តេចដែលបានបន្ទាបបន្ថោកដល់ការថ្វាយបង្គំរូបសំណាក បានសង់ព្រះវិហារ ដើម្បីថ្វាយបង្គំឡើងវិញ ហើយបានហៅពួកសាសន៍យូដាអោយប្រតិបត្តិថ្ងៃបុណ្យរំលង។



Copyright © Gratia Dei Sola Media

(១ពង្សាវតាក្សត្រ ១៥:៩-១៥; ២របាក្សត្រ ២៩:១-៩; ១ពង្សាវតាក្សត្រ ២២:៤២-៤៣; ២របាក្សត្រ៣០:១-២; ២ពង្សវតាក្សត្រ ២២:១-២; ២៣:១៩-២៥ ។ល។)

**៨. តើហោរាមួយណាដែលព្រះតាំងឡើង ជាពិសេសដើម្បីអោយបង្រៀនដល់សាសន៍យូដាអោយដើរតាមផ្លូវរបស់ទ្រង់?**

គឺហោរាអេសាយ និងហោរាយេរេមា ព្រះបានប្រាប់ពួកគាត់អោយដឹងថា ពេលវេលាទាសភាពនៃសាសន៍យូដាជិតមកដល់ហើយ ហើយសល់តែមនុស្សមួយចំនួនតូចប៉ុណ្ណោះ។ (អេសាយ១,យេរេមា១:១-២,៣:២៣-៤:៦)

**៩. តើព្រះជាម្ចាស់មានព្រះបន្ទូលអំពីព្រះគ្រីស្ទនៅក្នុងសម័យនោះដែរឬទេ?**

មែនហើយ តាមរយៈហោរាមីកាទ្រង់ថែមទាំងបញ្ជាក់ថាស្រុកបេថ្លេហិម គឺជាកន្លែងដែលព្រះអម្ចាស់យេស៊ូវនឹងត្រូវប្រសូត្រទៀតផង។(មីកា ៥:២)

**១០. តើសាសន៍យូដាបានងាកចេញពីផ្លូវដ៏អាក្រក់របស់គេឬទេ?**

ទេ! ពួកគេកាន់តែប្រព្រឹត្តអំពើអាក្រក់ខ្លាំងឡើងៗ ទោះបីជាអាណាចក្រ អ៊ីស្រាអែលបានកន្លងផុតទៅហើយក្តី។ (២ពង្សាវតាក្សត្រ២៣:២៦-២៧,២៤:៣-៩)



Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៤៥:៧-៨) [៧]ទ្រង់បានស្រឡាញ់សេចក្តីសុចរិត ហើយស្អប់ការទុច្ចរិត ហេតុនោះបានជាព្រះគឺជាព្រះនៃទ្រង់ បានចាក់ប្រេងថ្វាយទ្រង់ជាប្រេងនៃសេចក្តីត្រេកអរសាទរ លើសជាងពួកសំឡាញ់នៃទ្រង់ [៨]ព្រះពស្ត្រទ្រង់ផ្សាយក្លិនក្រអូប ដោយជ័រល្វីងទេសក្រឹស្នា និងកំញានមានព្សូរភ្លេង ចេញពីដំណាក់ភ្លុកបណ្តាលអោយទ្រង់សប្បាយឡើង។



Copyright © Gratia Dei Sola Media

# មេរៀនទី ២០
# សាសន៍យូដាបានទទួលការឃុំឃាំង

១. **តើព្រះជាម្ចាស់បានដាក់ទោស អំពើអាក្រក់របស់យូដាយ៉ាងដូចម្តេច?**
ព្រះបញ្ជូនស្តេចនេប៊ូក្នេសាអោយយកសាសន៍យូដាធ្វើជាទាសករ។ (២របាក្សត្រ ៣៦)

២. **តើរាស្ត្ររបស់ព្រះជាម្ចាស់ភាគច្រើនត្រូវបានគេនាំចូលទៅក្នុងទឹកដីនៃនឹមទាសករដែរឬទេ?**
មែនហើយ ឧទាហរណ៍ ដានីយ៉ែន និងមិត្តគាត់៣នាក់ទៀតជាដើម។ (ដានីយ៉ែល១:១-៤,៦-៧)

៣. **តើស្តេចនេប៊ូក្នេសាបាននាំទាសករទៅកាន់ទីក្រុងណា?**
គឺទៅទីក្រុងបាប៊ីឡូន ដែលជារាជធានីនៃចក្រភពបាប៊ីឡូន។ (យេរេមា៥៣:២៨-៣២)

៤. **ប៉ុន្តែ តើព្រះមិនបានសន្យានឹងសាសន៍អ៊ីស្រាអែលថាអោយពួកគេធ្វើជាម្ចាស់លើទឹកដីកាណានរហូតអស់កល្បទេឬអី?**
ទ្រង់បានសន្យាប្រាកដមែន តែការសន្យានោះបានសំរេចរួចរាល់នៅ ពេលដែលបែកចែកមរតកទឹកដីស្ថានសួគ៌កាណាន។ (វិវរណៈ:២១-២២:៧)



Copyright © Gratia Dei Sola Media

**៥. តើពួកព្រឹទ្ធាចារ្យបានយល់ថា សេចក្តីសន្យានេះចង់សំដៅទៅលើស្ថានសួគ៌មែនទេ?**

មែនហើយ ពួកគេមានបំណងចិត្តចង់បានប្រទេសមួយដែលប្រសើរជាងមុន វាប្រហែលនឹងស្ថានសួគ៌ដែរ។ (ហេព្រើរ ១១:១០, ១៣-១៦)

**៦. តើមានអ្វីបានកើតឡើងចំពោះព្រះវិហារ និងបល្ល័ង្ករបស់ស្តេចដាវីឌនៅក្នុងទីក្រុងយេរូសាឡិម?**

គឺត្រូវបានបំផ្លាញទាំងស្រុង ក្នុងពេលដែលទីក្រុងត្រូវបានឆេះឡើង។ (២ពង្សាវតាក្សត្រ២៥:៨-៩,១៧)

**៧. ហេតុអ្វីបានជាព្រះជាម្ចាស់សព្វព្រះហឫទ័យអោយបំផ្លាញចោលបែបនេះ?**

ព្រោះទ្រង់សព្វព្រះទ័យអោយរាស្ត្ររបស់ទ្រង់ បានសំឡឹងទៅឯបល្ល័ង្ករបស់ព្រះគ្រីស្ទ ក្នុងក្រុងយេរូសាឡិមថ្មីវិញម្តង។ (វិវរណៈ ៣:១១-១៣)

**៨. តើការរស់នៅក្រោមនឹមទាសភាពបានប៉ះពាល់ដល់អ្នកជឿយ៉ាងដូចម្តេចខ្លះ?**

ពួកគេបាននឹកហើយនឹកទៀតដល់ព្រះវិហារ ដែលជាកន្លែងព្រះអាស្រ័យគង់នៅ។ (ទំនុកដំកើង ១៣៧)



Copyright © Gratia Dei Sola Media

**៩. តើហោរាដានីយ៉ែលបង្ហាញជំនឿគាត់ ចំពោះព្រះបន្ទូលសន្យានៅបាប៊ីឡូនយ៉ាងដូចម្តេច?**

គាត់បានអធិស្ឋានដោយបែរមុខសំដៅទៅឯក្រុងយេរូសាឡិម ដែលជាកន្លែងព្រះវិហារបានតាំងនៅ (ដានីយ៉ែល៦:១០)។

**១០.តើនរណាបានលើកទឹកចិត្តដល់ពួកគេ អោយរំពឹងចាំនូវការវិលត្រឡប់របស់ពួកគេវិញ?**

គឺហោរា អេសេគាល ដែលជាមនុស្សម្នាក់ក្នុងចំណោមពួកឈ្លើយនៅមានទន្លេកេបារ។ (អេសេគាល ១)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៦៧:១-៤) [១]សូមព្រះអង្គអាណិតមេត្តាដល់យើងខ្ញុំ ហើយប្រទានពរផង សូមអោយព្រះភ័ក្រទ្រង់ភ្លឺមកដល់យើងខ្ញុំ [២]សូមអោយមនុស្សលោកបានស្គាល់ផ្លូវរបស់ទ្រង់ ហើយអោយអស់ទាំងសាសន៍ដទៃបានស្គាល់សេចក្តីសង្គ្រោះរបស់ទ្រង់ដែរ [៣]ឱព្រះអង្គអើយ សូមអោយជនទាំងឡាយសរសើរដល់ទ្រង់ អោយជនទាំងអស់សរសើរដល់ទ្រង់ [៤]ឱសូមអោយអស់ទាំងនគរបានអរសប្បាយ ហើយច្រៀងដោយអំណរចុះ។


Copyright © Gratia Dei Sola Media

# មេរៀនទី ២១
# ព្រះជាម្ចាស់ប្រោសប្រណីដល់ពួកចំណាប់ខ្មាំង

**១. តើសៀវភៅទំនាយមួយណា ដែលបានសរសេរក្នុងអំឡុងពេលស្ថិតក្រោមការជិះជាន់សង្កត់សង្កិន?**
ក្នុងបទគម្ពីរដានីយ៉ែល ដែលនិយាយអំពីការជិតយាងមកដល់នៃអាណាចក្រព្រះគ្រីស្ទ។

**២. តើព្រះជាម្ចាស់បានបើកសំដែង ពីការមកដល់នៃអាណាចក្រនេះដល់ស្ដេចនេប៊ូក្នេសាយ៉ាងដូចម្ដេច?**
តាមរយៈការសុបិននិមិត្តឃើញនូវរូបភាពដ៏ធំសំបើមមួយត្រូវបានបំផ្លាញចោល។ (ដានីយ៉ែល ២)

**៣. តើរូបភាពក្នុងសុបិននិមិត្តនេះដំណាងអោយអ្វី?**
ដំណាងអោយអាណាចក្រលោកីយទាំងមូល ដែលមានស្ដេចនេប៊ូក្នេសាជាប្រមុខ។ (ដានីយ៉ែល២:៣៧-៤៣)

**៤. តើរូបភាពក្នុងសុបិននិមិត្តនេះត្រូវបានបំផ្លាញយ៉ាងដូចម្ដេច?**
បំផ្លាញដោយដុំថ្ម ដែលជាដំណាងអោយអាណាចក្ររបស់ព្រះគ្រីស្ទ។ (ដានីយ៉ែល២:៤៤-៤៥)



Copyright © Gratia Dei Sola Media

**៥. តើដានីយ៉ែល និងមិត្តគាត់ទាំង៣នាក់ មានការរងទុក្ខដោយសារជំនឿពួកគេក្នុងអាណាចក្រនោះដែរឬទេ?**

មែនហើយ ពួកគាត់ត្រូវបានចាប់បោះទៅក្នុងឡភ្លើងនៅពេលដែលពួកគាត់បានបដិសេធ មិនថ្វាយបង្គំរូបសំណាកស្តេចនេប៊ូក្នេសា។ (ដានីយ៉ែល៣)

**៦. តើព្រះជាម្ចាស់បានការពារមិត្តភ័ក្រទាំង៣នាក់នេះដូចម្តេច?**

ព្រះអង្គបានចាត់ទេវតារបស់ទ្រង់អោយដើរកាត់ឡភ្លើងជាមួយពួកគេ។ (ដានីយ៉ែល៣:២៥-២៨)

**៧. តើព្រះជាម្ចាស់បានបើកសំដែងអោយស្តេចបេលសាសារឃើញពីការធ្លាក់ចុះនៃក្រុងបាប៊ីឡូនយ៉ាងដូចម្តេច?**

ដោយការសរសេរលើជញ្ជាំង រួចហោរាដានីយ៉ែលជាអ្នកបកស្រាយ។ (ដានីយ៉ែល ៥)

**៨. តើដានីយ៉ែលត្រូវបានការពារពួកខ្មាំងសត្រូវយ៉ាងដូចម្តេច?**

ព្រះបានរក្សាជីវិតគាត់ ពេលដែលគាត់នៅក្នុងរូងតោ។ (ដានីយ៉ែល ៦)



Copyright © Gratia Dei Sola Media

**៩. តើព្រះជាម្ចាស់រំដោះប្រជារាស្ត្រទ្រង់ចេញពីចំណាប់ខ្មាំង យ៉ាងដូចម្តេច?**

គឺរយៈពេល៧០ឆ្នាំ ក្រោយមកព្រះអង្គបានដកស្តេច ស៊ីរូស ចេញពីអំណាច ដោយអនុញ្ញាតិអោយរាស្ត្រទ្រង់ទៅថ្វាបង្គំនៅ ក្រុងយេរូសាឡិមវិញ។ (អែសរ៉ា១:១-២)

**១០.តើសាស៍យូដាបានរួចពីចំណាប់ខ្មាំង ហើយបានវិលទៅក្រុង យេរូសាឡិមវិញឬទេ?**

ទេ! មានសាសន៍យូដាជាច្រើនមានការពេញចិត្តក្នុងការបន្តរស់ នៅក្នុងក្រុងបាប៊ីឡូនតទៅទៀត។
(នាងអេស់ធើរ ២:៥-៧, ៣:៦)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៦៧:៤ខ-៧) [4]ត្បិតទ្រង់នឹង ជំនុំជំរះអស់ទាំង សាសន៍ដោយទៀតត្រង់ ហើយគ្រប់គ្រង អស់ទាំងនគរដែលនៅលើផែនដី [5]ឱព្រះអង្គអើយ សូមអោយ ជនទាំងឡាយសរសើរដល់ទ្រង់ អោយជនទាំងអស់សរសើរ ដល់ទ្រង់ចុះ [6]នោះដីនឹងបង្កើតផលឡើង ហើយព្រះដ៏ជាព្រះ នៃយើងខ្ញុំ ទ្រង់នឹងប្រទានពរមកយើងខ្ញុំ [7]ព្រះទ្រង់នឹងប្រទាន ពរមកយើងខ្ញុំជាពិត ហើយអស់ទាំងចុងផែនដីបំផុតនឹងកោត ខ្លាចដល់ទ្រង់ ។


Copyright © Gratia Dei Sola Media

# មេរៀនទី ២២
# សាសន៍អ៊ីស្រាអែលវិលត្រឡប់មកទឹកដីស្រុកកាណានវិញ

**១. តើអ្វីទៅជាកត្តាដែលនាំអោយពួកឈ្លើយ វិលមកស្វែងរកទីក្រុងបរិសុទ្ធវិញ?**

ពួកគេបានស្វែងរកឃើញក្រុងយេរូសាឡិម និងព្រះវិហារដែលសល់ពីការបាក់បែក។ (នេហេមា២:១២-១៨)

**២. ហេតុអ្វីបានព្រះជាម្ចាស់បង្គាប់អោយពួកគេ សាងសង់ព្រះវិហារឡើងវិញ?**

ព្រោះវាជាអត្ថន័យបញ្ជាក់ពីព្រះវត្តមានទ្រង់ ក្នុងចំណោមរាស្ត្រព្រះអង្គ។(អែសរ៉ា១:១-៥,១របាក្សត្រ២២:១៩,និក្ខមនំ ២៥:២២)

**៣. ហេតុអ្វីសព្វថ្ងៃនេះ យើងមិនថ្វាយបង្គំព្រះតែនៅព្រះវិហារដូចពីមុន?**

ព្រោះតែព្រះគ្រីស្ទគឺជាព្រះវិហាររបស់ព្រះជាម្ចាស់ ដូច្នេះ ហើយព្រះវិញ្ញាណទ្រង់គង់ក្នុងចិត្តយើង។
(វិវរណៈ ២១:២២, អេភេសូ ២:២២)

**៤. តើនរណាបានជំទាស់ពួកយូដាក្នុងការសង់ព្រះវិហារ និងក្រុងយេរូសាឡិម?**

គឺពួកសាសន៍សាម៉ារី និងអស់អ្នកដែលមិនជឿព្រះផ្សេងទៀតដែល រស់ក្នុងទឹកដីនោះ។ (អែសរ៉ា ៤)



Copyright © Gratia Dei Sola Media

**៥. ហេតុអ្វីបានពួកគេទាំងនោះព្យាយាមបញ្ឈប់សាសន៍យូដា?**

ពីព្រោះពួកគេបានស្អប់ព្រះជាម្ចាស់ និងស្អប់រាស្ត្ររបស់ព្រះអង្គ។ (នេហេមា២:១៩-២០,៤:១-៨)

**៦. តើសាសន៍យូដាអាចសាងសង់ព្រះវិហារបានសំរេចដែរឬទេ?**

មែនហើយ ស្តេចដារីយុស បញ្ជាអោយក្រុមទេសាភិបាលក្នុងតំបន់នោះចេញពីពួកគេ បើទោះបីជាមានការបង្ខិតបង្ខំអោយគាត់ប្រគល់នូវរបស់របរ ផ្សេងៗដែលត្រូវការសំរាប់ការងារនោះក៏ដោយ។ (អែសរ៉ា ៦)

**៧. តើប្រជាជនធ្វើដូចម្តេច ពេលដែលពួកគេសង់គ្រឹះនៃព្រះវិហាររួចរាល់?**

ពួកគេច្រៀងឆ្លងឆ្លើយគ្នា ដោយពាក្យសរសើរ ហើយអរព្រះគុណដល់ព្រះជាម្ចាស់។ (អែសរ៉ា ៣:១១)

**៨. តើប្រជារាស្ត្ររីករាយដែរឬទេ ពេលដែលព្រះវិហារត្រូវបានសង់រួចរាល់?**

ទេ! មានអ្នកខ្លះដែលបានឃើញទ្រង់ទ្រាយរបស់ព្រះវិហារពីមុនពួកគេស្រែកយំយ៉ាងខ្លាំង។ (អែសរ៉ា ៣:១២)



Copyright © Gratia Dei Sola Media

**៩. តើរាជ្យបល្ល័ង្ករបស់ស្ដេចដាវីឌត្រូវបានស្ដារឡើងវិញ ដែរឬទេ?**

ទោះបីជាគ្មានស្ដេចអង្គណា គង់លើបល្ល័ង្កព្រះបាទដាវីឌក៏ដោយ ក៏នៅតែមានខ្សែស្រឡាយរាជវង្សានុវង្សបន្តដដែល។ (យេរេមា៣៦:២៩-៣០, អេសាយ៩:៦-៧)

**១០.តើការប្រមូលផ្ដុំនៃរាស្ត្រព្រះជាម្ចាស់ក្នុងការវិលមកក្រុងយេរូសាឡិមវិញមានសារៈសំខាន់ដូចម្ដេច?**

ក្នុងនោះ គឺដើម្បីព្រះគ្រីស្ដអាចនឹងប្រសូត្រក្នុងទឹកដីសន្យា ជាមួយគ្នានេះដែរ វាក៏ជាសញ្ញាបង្ហាញពីការប្រមូលផ្ដុំគ្នានៃរាស្ត្រទ្រង់ក្នុងពួកជំនុំនៃសម្ព័ន្ធមេត្រីថ្មី។ (អែសរ៉ា៩, នេហេមា៨:១-៩:៣៨, ហាកាយ២:១៥-២៣, ទំនុកដំកើង៨៧,លូកា១:១-២:៥២)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១២២:១-៥) [១]កាលគេនិយាយមកខ្ញុំថា ចូរយើងចូលទៅក្នុងដំណាក់នៃព្រះយេហូវ៉ា នោះខ្ញុំមានចិត្តអំណរអរណាស់ [២]ឱក្រុងយេរូសាឡិម អើយ ជើងយើងឈរនៅខាងក្នុងទ្វាររបស់ឯងហើយ [៣]យេរូសាឡិម អើយ ឯងបានសង់ឡើងដូចជាទីក្រុងដែលណែនណាន់ជាប់គ្នា [៤]ជាកន្លែងដែលអស់ទាំងពូជអំបូរ គឺពូជអំបូរនៃព្រះយេហូវ៉ាគេឡើងទៅតាមទំលាប់នៃសាសន៍អ៊ីស្រាអែល ដើម្បីនឹងអរព្រះគុណដល់ ព្រះនាមព្រះយេហូវ៉ា [៥]ត្បិតនៅទីនោះមានបល្ល័ង្កតាំងឡើងសំរាប់ការវិនិច្ឆ័យ គឺជាបល្ល័ង្កទាំងប៉ុន្មាននៃរាជ្យវង្សដាវ។


Copyright © Gratia Dei Sola Media

# សម័យកាលទី ៥
# ប្រជារាស្ត្រអ៊ីស្រាអែលនៅក្នុងទឹកដីស្រុកកាណាន ដើម្បីទទួលកំណើរព្រះគ្រីស្ទ

## មេរៀនទី ២៣
## ព្រះជាម្ចាស់ការពារប្រជារាស្ត្រសម្ព័ន្ធមេត្រីរបស់ព្រះអង្គ

**១. តើព្រះគម្ពីរមួយណាដែលប្រាប់យើងអំពីសាសន៍យូដា ដែលបាននៅសល់លើទឹកដីនៃចំណាប់ខ្មាំង?**

គឺព្រះគម្ពីរ អេសធើរ ដែលត្រូវបានគេដាក់តាមឈ្មោះក្មេងស្រីសាសន៍ យូដាម្នាក់ដែលបានក្លាយជាមហេសីរបស់ស្តេចស្រុកពើរស៊ី។

**២. តើក្នុងព្រះគម្ពីរអេសធើរបានបង្រៀនអំពីសេចក្តីពិតយ៉ាងដូមម្តេច?**

ក្នុងព្រះគម្ពីរនេះបានបង្រៀន អោយយើងដឹងថាមនុស្សហាម៉ានគ្មានផ្លូវនឹងបំផ្លាញពួកជំនុំព្រះជាម្ចាស់បានឡើយ។ (នាងអេសធើរ៨:៧-១១,១៦-១៧)



Copyright © Gratia Dei Sola Media

**៣. តើក្នុងសម័យកាលនោះហាម៉ានជាមនុស្សអាក្រក់ព្យាយាម បំផ្លាញពួកជំនុំព្រះឬទេ?**

មែនហើយ! សាតាំងបានព្យាយាមប្រើប្រាស់ហាម៉ានជាមនុស្ស អាក្រក់ ដើម្បីអោយសម្លាប់សាសន៍យូដាទាំងអស់ចោល។ (អេសធើរ ៣)

**៤. ហេតុអ្វីបានហាម៉ានព្យាយាមបៀតបៀនដល់ពួកជំនុំនៃព្រះ?**

ព្រោះគេស្អប់ម៉ាដេកាយដែលជាសាសន៍យូដា។ (នាងអេសធើរ៣:១-៦)

**៥. តើគេបានធ្វើដូចម្តេច ដើម្បីសម្លាប់ពួកយូដាទាំងអស់នោះ?**

គេបានបញ្ចុះបញ្ចូលស្តេច អ័ហាស៊ូរុស អោយបង្កើតច្បាប់មួយ ឡើង ដើម្បីអោយសាសន៍យូដាទាំងអស់មានទោសរហូតដល់ ស្លាប់។ (អេសធើរ ៣:៨)

**៦. តើព្រះបំផ្លាញគំរោងការណ៍របស់ហាម៉ានយ៉ាងដូចម្តេច?**

ព្រះអង្គបានបណ្តាលចិត្តអោយព្រះនាងអេសធើរ ទូលសូម អោយស្តេចទុកជីវិតនាង និងសាសន៍នាងផងដែរ។ (អេសធើរ ៧:១-៤)



Copyright © Gratia Dei Sola Media

**៧. តើនរណាប្រាប់អោយព្រះនាងអេសធើរ ទូលសូមអោយស្តេចទុកជីវិតនាង និងសាសន៍នាង?**

គឺម៉ាដេកាយ ជាឪពុកមានាង ជាអ្នកដែលបាននាំនាងអោយចូលមកក្នុងទឹកដីដែលមិនជឿលើព្រះនេះ។

**៨. តើការដាក់ទោសបានធ្លាក់មកលើហាម៉ានដូចម្តេច?**

ស្តេចយកគេទៅព្យួរករលើឈើដែលគេដំឡើងទុកសំរាប់ព្យួរករ ម៉ាដេកាយជំនួសវិញ។ (អេសធើរ ៧:៧-១០)

**៩. តើវាជាអំពើបាបសំរាប់សាសន៍យូដា ដូចជាម៉ាដេកាយ និងនាងអេសធើរ ដែលបន្តរស់ក្នុងទឹកដីចំណាប់ខ្មាំងដែរឬទេ?**

មែនហើយ ពួកគេហាក់ដូចជាមិនចាប់អារម្មណ៍នៅក្នុងព្រះវិហារ និងព្រះបន្ទូលសន្យានៃសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់។ (ហេព្រើរ ១១:៨-១០, ១៣-១៦, និក្ខមនំ ២៥:២២, នាងរស់ ១:១-៦,១៩-២១)

**១០.តើយើងរៀនពីប្រវត្តិសាស្រ្តនេះយ៉ាងណាដែរ?**

ព្រះជាម្ចាស់មានព្រះទ័យមេត្តាករុណាចំពោះរាស្រ្តទ្រង់ ហើយសូម្បីតែមនុស្សមានបាប ក៏ទ្រង់ប្រើគេឱ្យមកសង្គ្រោះពួកជំនុំរបស់ទ្រង់ដែរ។

(នាងអេសធើរ ៨:១,៨:១៥-៩:៥, យេរេមា ២៩:៧)



Copyright © Gratia Dei Sola Media

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១២២:៦) ⁶ចូរអធិស្ឋានអោយក្រុងយេរូសាឡិមបានសេចក្តីសុខចុះ សូមអោយអស់អ្នកដែលស្រឡាញ់ឯងបានសេចក្តីចំរើន។



Copyright © Gratia Dei Sola Media

# មេរៀនទី ២៤
# អំពើបាបបានបង្ហាញខ្លួនក្នុងទឹកដីស្រុកកាណាន ជាថ្មីម្តងទៀត

១. **តើព្រះជាម្ចាស់បានបញ្ជូននរណាទៅលើកទឹកចិត្តសាសន៍យូដាអោយកសាងកំផែងក្រុងយេរូសាឡិម និងនៅរក្សាភាពស្មោះត្រង់ទៅកាន់ព្រះជាម្ចាស់?**
អែសរ៉ា ជាអ្នកនិពន្ធ និងនេហេមា ជាអ្នកបំរើពែងរបស់ស្តេច។ (នេហេមា២:១៧-១៨,៣,៩:៦,៨)

២. **តើសាសន៍យូដាស្តាប់ឱវាទព្រះឬទេ បន្ទាប់ពីគេបានទៅក្រុងយេរូសាឡិមវិញ?**
ទេ! វាបានក្លាយជាការជាក់ស្តែងយ៉ាងឆាប់រហ័ស ដែលមានមនុស្សអាក្រក់ជាច្រើនក្នុងចំណោមពួកគេ។

៣. **តើសាសន៍យូដាបានប្រព្រឹត្តអំពើបាបបែបណាខ្លះ?**
ពួកគេរៀបការជាមួយជាតិសាសន៍ដែលមិនជឿព្រះ ហើយថែមទាំង ទិញលក់ទំនិញក្នុងថ្ងៃឈប់សំរាកទៀតផង។ (នេហេមា ១៣:១៦,២៣)

៤. **តើពួកសម្តេចសង្ឃបានប្រព្រឹត្តអំពើបាបបែបណាខ្លះ?**
ពួកគេរៀបការជាមួយសាសន៍ដែលមិនជឿព្រះ ហើយប្រព្រឹត្តអំពើពុករលួយក្នុងសង្ឃភាពទៀតផង។



Copyright © Gratia Dei Sola Media

(នេហេមា ១៣:២២,២៨-២៩,អែសរ៉ា ៩:១-៣)

**៥. ហេតុអ្វីបានជាហោរា ហាកាយបន្ទោសដល់សាសន៍យូដានាសម័យនោះ?**

ព្រោះពួកសាសន៍យូដាសង់ផ្ទះរបស់ខ្លួនយ៉ាងប្រណីតៗ ជំនួសអោយការកសាងព្រះវិហារវិញ។ (ហាកាយ ១:១-៥)

**៦. តើហោរាម៉ាឡាគី បានស្ដីបន្ទោសដល់ប្រជារាស្ត្រពីអំពើបាបបែបណា?**

គាត់និយាយទៅប្រជារាស្ត្រថា ពួកគេបានលួចព្រះជាម្ចាស់ពីការថ្វាយដង្វាយ១ភាគក្នុង១០។ (ម៉ាឡាគី ៣:៨)

**៧. តើអំពើអាក្រក់ទាំងឡាយដែលមានក្នុងចំណោមសាសន៍យូដាបង្ហាញអោយ យើងឃើញដូចម្ដេច?**

គឺគ្មាននរណាម្នាក់បានទទួលព្រះពរ ដែលព្រះជាម្ចាស់បានសន្យាក្នុងព្រះគ្រីស្ទទាល់តែសោះ។ (មីកា ៧)

**៨. តើមានអ្វីទៀតដែលអំពើអាក្រក់បើកសំដែងអោយយើងឃើញ?**

ធ្វើអោយព្រះគ្រីស្ទមិនអាចយាងមកបាន លើកលែងតែយាងមកតាមរយៈព្រះគុណដ៏អស្ចារ្យនៃព្រះអម្ចាស់ប៉ុណ្ណោះ។



Copyright © Gratia Dei Sola Media

**៩. តើការលន់តួបែបណា ដែលសាសន៍អ៊ីស្រាអែលមួយចំនួនបានបង្ហាញ?**

ព្រះជាម្ចាស់ស្មោះត្រង់ចំពោះព្រះបន្ទូលសន្យារបស់ទ្រង់ជានិច្ច ហេតុនេះទើបនៅសល់មនុស្សមួយចំនួន នៅតែទន្ទឹងរង់ចាំការយាងមករបស់ព្រះគ្រីស្ទ។ (ម៉ាឡាគី ៣:១៦)

**១០. តើព្រះជាម្ចាស់មានព្រះបន្ទូលពីភាពស្មោះត្រង់របស់ទ្រង់តាមរយៈហោរាម៉ាឡាគីយ៉ាងដូចម្ដេច?**

ទ្រង់ប្រកាសថា "ត្បិតអញ គឺយេហូវ៉ា អញមិនប្រែប្រួលឡើយ ហេតុនេះ ឱពួកកូនចៅយ៉ាកុបអើយ ឯងមិនត្រូវវិនាសទេ"។ (ម៉ាឡាគី ៣:៦)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ១២២:៧-៩) [៧]សូមអោយមានសេចក្ដីសុខនៅខាងក្នុង កំផែងឯង ហើយសេចក្ដីចំរើននៅក្នុងព្រះរាជវាំងរបស់ឯង [៨]ព្រោះយល់ដល់ពួកបងប្អូន និងពួកមិត្រសំឡាញ់របស់អញបានជានឹងពោលឥឡូវថា សូមអោយមានសេចក្ដីសុខនៅខាងក្នុងឯងចុះ [៩]ដោយយល់ដល់ដំណាក់នៃព្រះយេហូវ៉ា ជាព្រះនៃយើងរាល់គ្នា នោះអញនឹងស្វែងរកសេចក្ដីល្អដល់ឯង។



Copyright © Gratia Dei Sola Media

# មេរៀនទី ២៥
# ការប្រុងប្រៀបខ្លួនសំរាប់ការយាងមករបស់ព្រះគ្រីស្ទ

**១. តើសាសន៍អ៊ីស្រាអែលមានស្តេចផែនដី សោយរាជ្យទៀតទេ ក្រោយពីពួកគេបានវិលត្រឡប់មកពីទឹកដីចំណាប់ខ្មាំងវិញ?**

ទេ! អ៊ីស្រាអែលត្រូវបានត្រួតត្រាដោយពួក ពើរស៊ី និងពួកក្រិក ហើយក្នុងសម័យព្រះយេស៊ូវ អ៊ីស្រាអែលត្រូវបានត្រួតត្រាដោយចក្រភពរ៉ូម។ (លូកា៣-១,កិច្ចកា២:៩-១១)

**២. តើសាសន៍យូដាគ្រប់គ្រងដោយខ្លួនឯង ក្នុងគ្រប់សម័យកាលទាំងអស់នោះឬ?**

មានពេលមួយពួកគេត្រូវត្រួតត្រាដោយមនុស្សមួយក្រុម ដែលត្រូវបានគេហៅថា ក្រុមជនបដិវត្តន៍សាសនាយូដា។

**៣. តើការថ្វាយបង្គំបែបណា ដែលបានក្លាយជាទីពេញនិយម បន្ទាប់ពីបានវិលទៅទឹកដីស្រុកកាណានវិញ?**

សាសន៍យូដាបានប្រមូលផ្តុំគ្នា ក្នុងសាលាប្រជុំនៅថ្ងៃឈប់សំរាកដើម្បីអាននិងពន្យល់ពីក្រឹត្យវិន័យ ហើយអធិស្ឋាន។ (ម៉ាថាយ៦:៥,៩:៣៥)

**៤. តើក្នុងអំឡុងពេលចាប់ពីវិលចូលទៅស្រុកកាណាន រហូតដល់ព្រះគ្រីស្ទយាងមកមានលក្ខណៈដូចម្តេច?**

វាគឺជាដំណាក់កាលមួយដែលពោរពេញ ទៅដោយការបៀតបៀនយ៉ាងខ្លាំង ពីព្រះវិហារទៅព្រះវោហារមួយទៀតបន្តៗគ្នា។



Copyright © Gratia Dei Sola Media

**៥. តើមានអ្វីបានកើតឡើងចំពោះសាសន៍យូដា ពេលដែលមានការបៀតបៀនពីស្តេចដែលមិនជឿលើព្រះដូច្នេះ?**

សាសន៍យូដាបានខ្ចាត់ខ្ចាយទៅគ្រប់ជាតិសាសន៍ ក្នុងសកលលោកនេះ។ (កិច្ចកា២:៩-១១)

**៦. ហេតុអ្វីព្រះសព្វព្រះហឫទ័យអោយចក្រភពរ៉ូមត្រួតត្រាលើរាស្រ្តទ្រង់?**

ជាការពិត ដើម្បីអោយដំណឹងល្អ បានរីករាលដាលបានយ៉ាងទូលំទូលាយដល់ទីឆ្ងាយៗក្រោយពីការសុគត ហើយរស់ឡើងវិញរបស់ព្រះយេស៊ូវ។ (កិច្ចការ ១០:១-៨, រ៉ូម១៥:២៣-២៥)

**៧. តើការបំរើនេះនាំអោយរីករាលដាលនៃដំណឹងល្អដូចម្តេច?**

ពិភពលោកនេះរួមគ្នាជាភាសាតែមួយ ហើយពួកសាវ័កអាចនឹងអាចធ្វើដំណើរដោយសេរី ពីប្រទេសមួយទៅប្រទេសមួយទៀត។

**៨. ប៉ុន្តែ តើព្រះមិនបានសន្យាថា នឹងមានព្រះរាជសារមួយមិនអនុញ្ញាតិអោយចេញពីស្រុកយូដា ឡើយដរាបដល់ព្រះមែស្ស៊ីមកទេឬអី?**

ពិតមែន ធ្វើដូច្នេះគឺដើម្បីពូជហ្លួងដាវីឌ ត្រូវបានការពាររហូតដល់ព្រះ គ្រីស្ទប្រសូត្រមក។ (លូកា ១:២៧, ៣២ និង ២:១-៥)



Copyright © Gratia Dei Sola Media

**៩. តើព្រះគ្រីស្ទ គឺជាព្រះមែស្ស៊ីដែលព្រះបានសន្យាជាស្ដេចមួយអង្គដែលនឹងគង់លើបល្ល័ង្កព្រះបាទដាវីឌរហូតនោះមែនទេ?**

ពិតមែនហើយ ព្រោះព្រះអង្គគឺជាអ្នកសង្គ្រោះសំរាប់មនុស្សទាំងអស់ដែលបានបញ្ជាក់ប្រាប់នៅក្នុងសម្ព័ន្ធមេត្រីចាស់។ (លោកុប្បត្តិ៤៩:១០, អេសាយ៩:៦-៧)

**១០.ហេតុអ្វីបានជាគេហៅព្រះអង្គថា ព្រះមែស្ស៊ី?**

ព្រោះទ្រង់ជ្រាបជាក់ច្បាស់ថានឹងមានជ័យជំនះ លើខ្មាំងសត្រូវទាំងឡាយហើយប្រទានអោយយើងសំរាក រហូតអស់កល្ប។ (អេសាយ៩:៦, ទំនុកដំកើង ២)

**ខគម្ពីរចងចាំបន្ថែម៖** (ទំនុកដំកើង ៨៩:១-៤) [១]ទូលបង្គំនឹងច្រៀងពីព្រះគុណ ព្រះយេហូវ៉ាជាដរាប មាត់ទូលបង្គំនឹងសំដែងអោយស្គាល់សេចក្តីស្មោះត្រង់របស់ទ្រង់ រហូតដល់អស់ទាំងដំណតទៅ [២]ត្បិតទូលបង្គំបានពោលហើយថា ព្រះគុណនឹងបានតាំងឡើង អោយនៅអស់កល្បជានិច្ច ទ្រង់ក៏នឹងតាំងសេចក្តីស្មោះត្រង់របស់ទ្រង់នៅលើស្ថានសួគ៌ផង [៣]អញបានតាំងសញ្ញានឹងអ្នកដែលអញបានរើសតាំង អញនឹងស្បថនឹងដាវីឌជាអ្នកបំរើអញថា [៤]អញនឹងតាំងពូជពង្សឯងអោយនៅអស់កល្បជានិច្ច ក៏នឹងដំកល់រាជ្យឯងអោយនៅគ្រប់ទាំងដំណតទៅ។



Copyright © Gratia Dei Sola Media